ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ

# សៀវភៅបច្ចេកទេសចិញ្ចឹមជ្រូក

# ជាលក្ខណៈគ្រួសារ





ឆ្នាំ ២០១៧

សៀវភៅនេះរៀបរៀង និងបោះពុម្ពដោយនាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។

រក្សាសិទ្ធដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វរាល់ការផលិតឡើងវិញនៃផ្នែកខ្លះ ឬទាំងស្រុងសៀវភៅនេះត្រូវបានការអនិញ្ញាតិពីអ្នកបោះពុម្ពជាមុនជាលាយលក្ខអក្សរ។

**អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ**

អាសយដ្ឋាន: ផ្លូវលេខ៣៧១ ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌស្ទឹងមានជ័យ រាជធានីភ្នំពេញ
លេខទូរសព្ទ : ០២៣ ៨៨៤ ៣៤៥ / ០១២ ៩៨២ ៩២៧

ម.ព.ឯ.ក AIDOC
Code: 242-025
Date:
Donated by:

# មាតិកាអត្ថបទ

ទំព័រ

១-អារម្ភកថា.....III

២-សេចក្តីផ្តើម.....១

១- កត្តាពូជ.....៣

១.១.១-ពូជជ្រូកនាំចូល.....៣

១.១.២- ពូជជ្រូកកូនកាត់.....៥

១.១.៣- ពូជជ្រូកក្នុងស្រុក.....៥

២- ការជ្រើសរើសពូជ.....៧

២.១.១- ការជ្រើសរើសកូនជ្រូកមេទុកធ្វើពូជ.....៧
២.១.២-ការជ្រើសរើសកូនជ្រូកទុកធ្វើបា.....៨
៣. ថែទាំជ្រូកមេ.....៨
៣.១.១.ការថែទាំមេជ្រូកមុនពេលបង្កាត់.....៨
៣.១.២.ការបង្កាត់.....៩
- សញ្ញានៃការរកឈ្មោល.....១០
- ពេលវេលានៃការដាក់ឈ្មោល.....១០
- ការបង្កាត់ជាន់ឈាម.....១១

៣.១.៣.ការផើមរបស់មេជ្រូក.....១១
.៣.១.៤- ការថែទាំមេជ្រូកក្នុករយៈពេលផើម.....១២
៣.១.៥. ការបង្កើតកូន.....១៣
- សញ្ញាបញ្ជាក់ថាមេជ្រូកជិតកើតកូន:.....១៣

៣.១.៦. ការបំបៅកូន.....១៥
៣.១.៧.ការចិញ្ចឹមកូនជ្រូកកំព្រា ឬកូនជ្រូកកើតលើសពីចំនួនដោះមេ.....១៧
៣.១.៨. ការផ្តាច់ដោះកូនជ្រូក.....១៨
៣.១.៩.ការវិលត្រឡប់រកឈ្មោលរបស់មេជនរូកក្រោយពេលផ្តាច់ដោះ.....១៩
៣.១.១០. ការថែទាំ និងប្រើប្រាស់ជ្រូកបា.....១៩

៣.២- ការថែទាំអនាម័យ និងសុខភាព.................................... ២០
៣.២.១- ការធ្វើអនាម័យទីកន្លែងរស់នៅ.................................... ២០
.៣.២.២- ការធ្វើអនាម័យលើខ្លួនសត្វ.................................... ២១
៣.២.៣- ការធ្វើអនាម័យលើចំណីអាហារ និងទឹក.................................... ២១
៤- បញ្ហាកើតឡើងលើមេ និងបាជ្រូក.................................... ២១
៤.១.១- មេជ្រូកស៊ីកូន.................................... ២១
៤.១.២ជ្រូកមេកើតកូនហើយមិនធ្លាក់សុក.................................... ២២
៤.១.៣- មេជ្រូកកើតកូនតិច.................................... ២២
៤.១.៤- មេជ្រូកកើតកូនធំតូចមិនស្មើគ្នា.................................... ២២
៤.១.៥. មេជ្រូកខ្វះទឹកដោះឱ្យកូនបៅ.................................... ២៣
៤.១.៦- បាជ្រូកបាត់បង់សមត្ថភាពបង្កាត់.................................... ២៣
៤.១.៧- បាជ្រូកផ្តល់កូនតិច.................................... ២៤
៥- ការចិញ្ចឹមជ្រូកយកសាច់.................................... ២៦
៥.១.១. ការជ្រើសរើសកូនជ្រូកមកចិញ្ចឹម.................................... ២៦
៥.១.២ អំពីទ្រុង ស្នូកទឹក និងស្នូកចំណី.................................... ២៨
៥.១.៣ ចំណី និងការផ្តល់ចំណី.................................... ៣៥
៦- សុខភាពសត្វ.................................... ៤៤
៦.១.១ អនាម័យ និងការថែទាំ.................................... ៤៩
៦.១.២ វិធានការការពារ.................................... ៤៩
៧.ឯកសារយោង.................................... ៥៣

# អារម្ភកថា

សៀវភៅ "ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ " ត្រូវបានចងក្រងឡើងដោយផ្អែក លើបទពិសោធន៍ជាក់ស្តែង សៀវភៅដែលមានស្រាប់ និងឯកសារបច្ចេកទេសពីបណ្តាប្រទេសផ្សេងៗស្តីពីការចិញ្ចឹមជ្រូក និងបទពិសោធន៍អនុវត្តជាក់ស្តែង។ បន្ថែមលើខ្លឹមសារបច្ចេកទេស ក្រុមការងារបានរៀបចំបញ្ចូលនូវរូបភាពអនុវត្តជាក់ស្តែង និងប្រើពាក្យបច្ចេកទេសសាមញ្ញៗដែលងាយស្រួលយល់ និងអាចយកទៅអនុវត្តបាន។

ឯកសារនេះមានគោលបំណងជួយជំរុញផលិតកម្មជ្រូកដែលស្របទៅនឹងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍បសុសត្វរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ២០១៦-២០២៥ ក្នុងការលើកកំពស់សុខភាពសត្វ និងផលិតកម្មសត្វ ដែលចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិការលើកកំពស់សន្តិសុខស្បៀង សុវត្ថិភាពចំណីអាហារ និងអនុផលផ្សេងៗទៀតសម្រាប់តម្រូវការម្ហូបអាហារ ដែលកំពុងមានកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេសការលើកកំពស់អាហាររូបត្ថម្ភ និងជីវភាពកសិករខ្នាតតូច និងសហគមន៍ជនបទ។

ខ្ញុំសូមកោតសរសើរដោយស្មោះចំពោះស្នាដៃរៀបចំនិពន្ធសៀវភៅនេះឡើងដោយលោក **គា ផា** អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម។ ខ្ញុំសូមថ្លែងអំណរគុណ ចំពោះអ្នកពាក់ព័ន្ធទាំងអស់ក្នុងការចូលរួម ផ្តល់គំនិតផ្តួចផ្តើមនិងកែសម្រួលដល់ការរៀបចំតាក់តែងសៀវភៅបច្ចេកទេសស្តីពីការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ ដែលរួមមាន៖ លោកស្រីបណ្ឌិត **អុក សាមិន** អគ្គនាយករងនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ, លោក **លឿង វ៉ាន់អៀង** អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម, លោក **ថោង សំណាង** អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម, លោកស្រី **ហុក ច័ន្ទផល្លាត** ប្រធានការិយាល័យផ្សព្វផ្សាយបច្ចេកទេស, លោក **ឃួន ម៉េងឡុង** អនុប្រធានការិយាល័យផ្សព្វផ្សាយបច្ចេកទេស និងលោក **ព្រាប ប្រាជ្ញា** អនុប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីចូលរួមកែលម្អ សៀវភៅបច្ចេកទេសនេះ ដើម្បីបម្រើផលប្រយោជន៍នៃការអភិវឌ្ឍអនុវិស័យផលិតកម្មសត្វនៅកម្ពុជា។

ខ្ញុំសង្ឃឹមជឿជាក់ថា សៀវភៅនេះនឹងក្លាយជាមូលដ្ឋានគ្រឹះ សម្រាប់អ្នកចិញ្ចឹមសត្វ សិស្ស និស្សិតក្នុងការបង្កើនចំណេះដឹង និងជំរុញលើកកំពស់ការចិញ្ចឹមសត្វ ជាពិសេសពង្រឹងការគ្រប់គ្រងខ្សែសង្វាក់ផលិតកម្មជ្រូកមានលក្ខណៈប្រកួតប្រជែង និងប្រែក្លាយជាមុខរបរសម្រាប់សេដ្ឋកិច្ចគ្រួសារ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**

**អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ**

**សេន សុវណ្ណ**

ដូចនេះយើងមានមូលដ្ឋានគ្រឹះដ៏ល្អសម្រាប់ការអភិវឌ្ឍន៍វិស័យនេះ ដើម្បីប្រើប្រាស់ឱកាសនិងសក្តានុពលដែលមានស្រាប់សម្រាប់ជួយដល់កសិករ គាំទ្រដល់ការអភិវឌ្ឍន៍វិស័យផលិតកម្មសត្វប្រកបដោយនិរន្តរភាព ធានាបាននូវសន្តិសុខស្បៀង សុវត្ថិភាពម្ហូបអាហារ ការធ្វើពាណិជ្ជកម្មប្រកបដោយប្រាក់ចំណេញ កាត់បន្ថយភាពក្រីក្រ និងរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ។

ជាទូទៅ ការចិញ្ចឹមជ្រូករបស់កសិករគឺចិញ្ចឹមតាមទំលាប់ និងតាមបែបយថាផល ជាលក្ខណៈគ្រួសារ ខ្វះនៅបច្ចេកទេស និងបទពិសោធន៍ក្នុងការចិញ្ចឹមទាំងការជ្រើសរើសពូជ ការផ្តល់ចំណី ការសាងសង់ទ្រុង ការថែទាំងផ្នែក សុខភាព និងព័ត៌មានទីផ្សារ ការចិញ្ចឹមសត្វជ្រូក ត្រូវបានអនុវត្តមាន២របៀបគឺៈ ការចិញ្ចឹមជ្រូកយកសាច់ និងការចិញ្ចឹមជ្រូកពូជ។

## - ការចិញ្ចឹមជ្រូកយកសាច់

ការចិញ្ចឹមជ្រូកសាច់ មិនសូវមានការលំបាកប៉ុន្មានទេ ព្រោះ ជាជ្រូកពុំមានលទ្ធភាពបន្តពូជបានទេ ដោយសារគេបានគ្រៀវយកពងស្វាស ឬអូវែចេញ ដើម្បីជម្រុញឲ្យជ្រូកលូតលាស់លឿន និងចិញ្ចឹមរយៈពេលខ្លី ។ តែកូនជ្រូកត្រូវជ្រើសរើសឲ្យបានល្អដូចជា ដឹងប្រវត្តិច្បាស់លាស់ ផ្តល់សាច់ក្រហមច្រើន ខ្លាញ់តិចស៊ីចំណីតិចតែលូតលាស់លឿននិងសាច់មានតម្រូវការទីផ្សារខ្ពស់។

## ការចិញ្ចឹមជ្រូកពូជ

ការចិញ្ចឹមជ្រូកពូជមានការលំបាក បើយើងធ្វើការប្រៀបធៀបទៅនឹងការចិញ្ចឹមពូជជ្រូកយកសាច់ ព្រោះជ្រូកដែលចិញ្ចឹមពុំបានធ្វើការគ្រៀវយកប្រដាប់បន្តពូជចេញទេគឺ ក្នុងគោលបំណងដើម្បីទុកវាឱ្យមានលទ្ធភាពក្នុងការបន្តពូជបាននៅពេលពេញវ័យ សម្រាប់យកកូនចិញ្ចឹមនាពេលអនាគត។ ចំណែកការចិញ្ចឹមគឺយើងត្រូវប្រើប្រាស់រយៈពេលវែងក្នុងការចិញ្ចឹម។ ប៉ុន្តែការទិញកូនជ្រូកមកដាក់ចិញ្ចឹមត្រូវជ្រើសរើសពូជជ្រូកណាដែលផ្តល់កូនល្អ កូនមានចំនួនច្រើន និងទិញពូជជ្រូកពីកន្លែងចិញ្ចឹមដែលយើងអាចជឿជាក់បាន ជាកន្លែងគ្មានផ្ទុះចម្លងផ្សេងៗ និងដឹងពីប្រវត្តិច្បាស់លាស់ ហើយជាពូជមិនរើសចំណី ស៊ីចំណីតិចតែផ្តល់ទិន្នផលខ្ពស់ដែលអាចឱ្យយើងចំណេញដើមទុនក្នុងការចំណាយទៅលើចំណី។ រីឯគុណភាពសាច់និងខ្លាញ់ គឺពូជជ្រូកដែលមានជាតិខ្លាញ់តិចសាច់ក្រហមខ្លាំង ដើម្បីធ្វើឱ្យអ្នកទិញហ៊ានឱ្យតម្លៃខ្ពស់ជាងពូជជ្រូកទូទៅ។ ប៉ុន្តែបច្ចុប្បន្ននេះ យើងបានសង្កេតឃើញនៅតាមទ្រុង កសិករក៏ដូច ជាកសិដ្ឋាន ចិញ្ចឹមសត្វ ជ្រូកផ្សេងៗបានចាប់ផ្តើមចិញ្ចឹមឡើងវិញ និងការចិញ្ចឹមជ្រូកក៏ក្លាយជាជំនួញយ៉ាងពិតប្រាកដ ដើម្បីដោះស្រាយជីវភាពគ្រួសារ និងបានចូលរួមចំណែកក្នុងការជួយពន្លឿនសេដ្ឋកិច្ចជាតិឱ្យមានការរីកចំរើននាពេលអនាគត់ផងដែរ។ ដោយយើងមើលឃើញពីអត្ថប្រយោជន៍ លើការងារចិញ្ចឹមជ្រូកដែលជាហេតុធ្វើឱ្យមានការរៀបចំឯកសារនេះឡើង។

ដើម្បីធ្វើឱ្យការចិញ្ចឹមសត្វជ្រូកនៅតាមរបស់កសិករ ឬអ្នកដែលមានបំណងចិញ្ចឹមទទួលបាន ជោគជ័យត្រូវយកចិត្តទុកដាក់ទៅលើកត្តាមួយចំនួនៈ ជ្រើសរើសពូជចំណីសាងសង់ទ្រុងថែទាំសុខភាព និងទីផ្សារ។

## ១- គន្លាពូជ

ពូជមានតួនាទីយ៉ាងសំខាន់ក្នុងការចិញ្ចឹមសត្វ ពូជជ្រូកនៅក្នុងប្រទេសកម្ពុជាមានច្រើនប្រភេទ។ ប៉ុន្តែបច្ចុប្បន្ននេះ ពូជជ្រូកនៅក្នុងប្រទេសកម្ពុជាមាន ២ប្រភេទគឺ ពូជជ្រូកនាំចូល និងពូជជ្រូកក្នុងស្រុក។

### ១.១.១- ពូជជ្រូកនាំចូល

ជាទូទៅ ពូជជ្រូកនាំចូលនេះសម្រាប់ផលិតកម្មបែបឧស្សាហកម្មភាគច្រើនគឺ ពូជជ្រូកយ៉កសៀរ ពូជឡែនដ្រាស និងពូជជ្រូកឌុយរ៉ុក ឬពូជកូនកាត់។ ពូជជ្រូកទាំង ៣ប្រភេទនេះ គឺវាផលិតសាច់ក្រហមបានច្រើន ប៉ុន្តែដោយរួមផ្សំជាមួយចំណី និងប្រសិទ្ធភាពរបស់ចំណីផងដែរ។ ប្រសិនបើការផ្តល់ចំណីចំនួន ២.៨គ.ក បានសាច់ជ្រូក ១គ.កបានន័យថាចំណីមានគុណភាព ។ ប៉ុន្តែពូជនេះបើប្រៀបធៀបទៅនឹងពូជក្នុងស្រុកវាមិនសូវធន់ទៅនឹងជម្ងឺ ហើយងាយរងនូវបញ្ហាផ្សេងៗពីអាកាសធាតុក្តៅ និងចំណីដែលមានគុណភាពអន់។

- **ពូជជ្រូកយ៉កសៀរ**

ជាពូជជ្រូកដែលមានលទ្ធភាពផ្តល់កូនបានល្អ អត្រាបង្កាត់ពូជជាប់ខ្ពស់ និងចំនួនកូននៅរស់ខ្ពស់ សុខភាពល្អងាយចិញ្ចឹមក្នុងស្ថានភាពនៅក្នុងប្រទេសកម្ពុជា។ ជ្រូកពូជយ៉កសៀរនេះមានដងខ្លួនវែង ពណ៌សភ្លៅធំ និងជើងរឹងមាំ ក្បាលតូច ត្រចៀកបញ្ឈរ ច្រមុះខ្លី ឆាប់ធំ អត្រាប្តូរចំណីទាប អត្រាសាច់ខ្ពស់ គុណភាពសាច់ និងសាច់ចម្លកល្អ កំណើនទំងន់គិតជាមធ្យម ១.០៣០គីឡូក្រាមក្នុង ១ថ្ងៃ និងកំរាស់ខ្លាញ់ខ្នងគិតជាមធ្យម ០.៩៨៤ស.ម។ ម្យ៉ាងទៀតយើងអាចប្រើប្រាស់កូនជំនាន់ក្រោយដើម្បីទុកធ្វើមេ ឬបាពូជបន្តទៀតបាន។





- **ពូជជ្រូកឡែនដ្រាស**

មានប្រភពនាំមកពីប្រទេសដាណឺម៉ាក។ ជាពូជជ្រូកដែលមានលទ្ធភាពផ្តល់កូនបានល្អ អត្រាបង្កាត់ពូជជាប់ខ្ពស់និងចំនួនកូននៅរស់ខ្ពស់ សុខភាពល្អ ងាយចិញ្ចឹមក្នុងស្ថានភាពនៅក្នុងប្រទេសកម្ពុជា។ ជ្រូកពូជឡែនដ្រាសនេះមានរោម និងស្បែកពណ៌ស ដងខ្លួនវែងជាងពូជជ្រូកប្រភេទផ្សេងៗ ត្រចៀកធំធ្លាក់ទៅមុខបន្តិច ក្បាលតូច និងច្រមុះវែង ត្រគាកធំ និងខ្នងកោង ប៉ុន្តែជើងក្រោយរបស់វាតូចមិនសូវរឹងមាំ ឆាប់ធំ

អត្រាប្តូរចំណីទាប  អត្រាសាច់ខ្ពស់ គុណភាពសាច់ និងសាច់ចំម្លកល្អ កំណើនទំងន់គិតជាមធ្យម ១.០១៦ គីឡូក្រាមក្នុង១ថ្ងៃ និងកំរាស់ខ្លាញ់ខ្នងគិតជាមធ្យម ០.៥៩ស.ម។ ម្យ៉ាងទៀតយើងអាចប្រើប្រាស់កូនជំនាន់ក្រោយដើម្បីទុកធ្វើមេ ឬបាពូជបន្តទៀតបាន។





- **ពូជជ្រូកឌុយរ៉ុក**

មានប្រភពនាំមកពីប្រទេស ណរវែសជាពូជជ្រូកដែលមានលទ្ធភាពផ្តល់កូនបានល្អ អត្រាបង្កាត់ពូជជាប់ខ្ពស់ និងចំនួនកូនរៅរស់ខ្ពស់ មានសុខភាពល្អ ងាយចិញ្ចឹមក្នុងស្ថានភាពនៅក្នុងប្រទេសកម្ពុជា។ ជ្រូកពូជឌុយរ៉ុកនេះមានដងខ្លួនវែងភ្លៅធំ  និងជើងរឹងមាំឆាប់ធំ  អត្រាប្តូរចំណីទាប អត្រាសាច់ខ្ពស់ គុណភាពសាច់ និងសាច់ចម្លកល្អ កំណើនទំងន់គិត ជាមធ្យម  ១.០១៦គីឡូក្រាមក្នុង០១ថ្ងៃនិងកំរាស់ខ្លាញ់ខ្នងគិតជាមធ្យម ០.៥៩ ស.ម។ ម្យ៉ាងទៀតយើងអាចប្រើប្រាស់កូនជំនាន់ ក្រោយដើម្បីទុកធ្វើមេ ឬបាពូជបន្តទៀតបាន។





### ១.១.២- ពូជជ្រូកកូនកាត់

ពូជនេះយកពូជក្នុងស្រុកមកបង្កាត់ជាមួយពូជនាំចូលសមស្របដែលនឹងទទួលបានទិន្នផលខ្ពស់។ គោលបំណងចំបងនៃការកែលំអរពូជ គឺដើម្បីបង្កើនសេដ្ឋកិច្ចនិងធន់អាកាសធាតុហើយធន់នឹងជំងឺ។ បើសិនការផ្តល់ចំណីអាហារតាមរូបមន្តត្រឹមត្រូវគឺវាអាចមានទំងន់ពី៨០-១០០គ.ក្រក្នុងអាយុទៅ៤ខែ។ ពូជជ្រូកកូនកាត់ជាពូជដ៏ល្អសំរាប់អ្នកដែលគ្មានលទ្ធភាព ទិញចំណីដែលមានគុណភាពខ្ពស់ ព្រោះពូជនេះមិនសូវរើសចំណី ធន់នឹងជំងឺ និងធំធាត់លឿន ។




### ១.១.៣- ពូជជ្រូកក្នុងស្រុក

ធន់នឹងអាកាសធាតុ ពូកែថៃកូន មិនរើសចំណី សាយកូន ពូជក្នុងស្រុកមានដូចជា៖

#### ❖ ពូជជ្រូកហៃណាំ

ពូជជ្រូកហៃណាំជាពូជជ្រូកមានវត្តមាននៅប្រទេសជាច្រើនក្នុងពិភពលោក។ វាមានប្រភពដើមកំណើតនៅប្រទេសចិន គេហៅថាពូជចិន ឬពូជមួង ឬពូជយូណាន។ នៅប្រទេសយើងគេហៅ ថាពូជហៃណាំ ជាឈ្មោះកោះមួយនៅប្រទេសចិន។

- **លក្ខណៈទូទៅ ៖** មានក្បាលវែង មុខចង្អៀត ខ្នងអែន ពោះប៉ោង មាឌតូចល្មម ត្រចៀកធ្លាក់ទៅមុខបន្តិច ច្រមុះទូលាយ ជើងកម្ពស់ល្មម មានសម្បុរស-ខ្មៅឬ ខ្មៅ-ស ឬក៏ស។
- **គុណសម្បត្តិ ៖** ស្រួលចិញ្ចឹម លក្ខណៈធននឹងជំងឺ។ កូនក្នុងមួយសំបុក អាចមានពី៩-១២ក្បាល ជាមធ្យម ១០ក្បាល។
- **គុណវិបត្តិ៖** ចិញ្ចឹមក្រធំ មានទម្ងន់ ៥០-៦០ គ.ក្រ ក្នុងអាយុ៦-៧ខែ។




## ❖ ពូជជ្រូកដំរី

ជាពូជចំណាស់ជាងគេក្នុងចំណោមពូជជ្រូកនៅប្រទេសកម្ពុជា។

- **លក្ខណៈទូទៅ**: ក្បាលធំខ្មៅ នៅចំកណ្តាលថ្ងាស មានផ្ទាំងពណ៌ស រាងត្រីកោណ ឬរាងទ្រវែង មាត់ស ពោះ និងជើងទាំងបួនពណ៌ស ហើយផ្ទាំងសនោះព័ទ្ធពីស្មារហូតដល់ផ្នែកពោះ មានស្នាមជ្រីវជ្រួញ ត្រង់ភ្នែក ស្លឹកត្រចៀកធំ ខ្នងខ្ពស់ក្រាស់ ដំណើរដូចដំរី។
- **គុណសម្បត្តិ**: រហ័សពេញវ័យ មានលទ្ធភាពសម្រប ខ្លួនតាមតំបន់ខុសៗគ្នា ល្មោភស៊ី ធន់នឹងជំងឺ កូនច្រើន និងពូកែចិញ្ចឹមកូន។ កូនក្នុង១សំបុកមានពី៨-១០ក្បាលជួនកាលមានរហូតដល់១៥ក្បាល
- **គុណវិបត្តិ**: ធំធាត់យឺតក្នុងអាយុ ៦-៧ ខែ អាចមាន ទម្ងន់ ៥០-៦០ គ.ក្រ ភាគរយសាច់ក្រហមទាបមានពី៣៦- ៣៨%។





## ❖ ជ្រូកកណ្តុរ

ពូជជ្រូកកណ្តុរជាពូជជ្រូកនៅអាស៊ី

- **លក្ខណៈទូទៅ** : រោមខ្មៅប្រែទៅប្រផេះ ប៉ុន្តែមានដុំពណ៌សនៅថ្ងាស ខ្នងអែន ពោះប៉ោង កកិតដី មាឌតូចល្មម ក្បាលដូចកណ្តុរ ត្រចៀកតូចត្រង់ទៅមុខ។
- **គុណសម្បត្តិ**: ស្រួលចិញ្ចឹម ធន់នឹងជំងឺ។ កូនក្នុងមួយសំបុក អាចមានដល់១៤ក្បាលទៅ ២៤ក្បាលជាមធ្យម ។

**គុណវិបត្តិ**:ចិញ្ចឹមក្រធំមានទម្ងន់៥០-៦០ គ.ក្រ ក្នុងអាយុ១២ខែ។ លទ្ធភាពបន្តពូជខ្សោយកូនតូច។





# ២.ការជ្រើសរើសពូជ

ការជ្រើសរើសពូជជ្រូកសម្រាប់បន្តពូជគឺជាការចាំបាច់ណាស់ ហើយធ្វើឡើងដោយប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ជាងការជ្រើសរើសពូជមកចិញ្ចឹម។ ចំពោះការជ្រើសរើសពូជជ្រូកដែលត្រឹមត្រូវ យើងអាចធានាបាននៅអត្រាបង្កាត់ជាប់ខ្ពស់ ការបង្កកំណើតបានល្អ ការផ្តល់កូនច្រើន ធំធាត់លឿន និងអត្រាងាប់របស់កូនមានកំរិតទាប ។

## ២.២.១ ការជ្រើសរើសកូនជ្រូកមេទុកធ្វើពូជ

ជ្រូកមេដែលបានធ្វើជ្រើសរើសសម្រាប់ទុកពូជត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម:

- ត្រូវមានដងខ្លួនវែង មានដោះយ៉ាងតិចចំនួន ១២ ស្មើនឹង ៦គូរ ហើយនៅត្រង់ជួរគ្នា
- ជាកូនជ្រូកដែលមានលក្ខណៈធំជាងគេនៅក្នុងចំណោមកូនជ្រូកក្នុងសំបុក
- ជាជ្រូកដែលមានជំហរត្រង់ល្អ ( មិនមានជើងកោង ឬវៃច )និងមានដំណើរត្រង់ល្អ
- ជាមេជ្រូកដែលមានមេបាល្អ(មានសមត្ថភាពផលិតកូនបានល្អ និងមានចំនួនកូនច្រើនក្នុងមួយសំបុក)នៅចន្លោះពេលមួយ និងមិនធ្លាប់កើតជម្ងឺឆ្លងសំខាន់ផ្សេងៗជាពិសេសជម្ងឺឆ្លងតាមផ្លូវបន្តពូជ។ ចំពោះមេជ្រូកបន្តពូជត្រូវដាក់ចិញ្ចឹមឲ្យនៅដាច់ដោយឡែកពីគេហើយមេជ្រូកបន្តពូជមិនត្រូវមានខ្លាញ់ច្រើនពេកទេ ព្រោះវានាំឲ្យមានការប៉ះពាល់ដល់ការបង្ករកំណើត។





## ២.២.២ ការជ្រើសរើសកូនជ្រូកទុកធ្វើបា

ដើម្បីជ្រើសរើសកូនជ្រូកទុកធ្វើបា គឺត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោមៈ

- ជាជ្រូកដែលមានជំហរត្រង់ល្អ(មិនមានជើងកោង ឬវៀច) និងមានដំណើរត្រង់ល្អ
- ជាកូនជ្រូកដែលមានមាឌធំ និងល្អជាងគេនៅក្នុងសំបុក
- មានពងស្វាសទាំងពីរធំ និងមានទំហំប្រហាក់ប្រហែលគ្នា
- មានមេបាល្អដែលមានសមត្ថភាពផ្ដល់កំណើតកូនបានល្អ និងមានចំនួនច្រើនក្នុងមួយសំបុក (អត្រាបង្កកំណើតខ្ពស់) និងមិនធ្លាប់កើតជំងឺឆ្លងផ្សេងៗ ជាពិសេសជំងឺតាមផ្លូវបន្តពូជ។





# ៣ ថែទាំជ្រូកមេ

## ៣.១.១ ការថែទាំមេជ្រូកមុនពេលបង្កាត់

ដំណាក់កាលនេះ ត្រូវឱ្យជ្រូកស៊ីចំណីដែលមានសារធាតុចិញ្ចឹមច្រើន និងគ្រប់គ្រាន់ ហើយចំណីទាំងនោះត្រូវសំបូរទៅដោយជាតិសាច់ សារធាតុរ៉ែ កាលស្យូម និងវីតាមីន ជាពិសេសគឺជាតិវីតាមីនអា។ ចំពោះជ្រូកញី គឺមិនត្រូវឱ្យវាធាត់ពេកទេ និងត្រូវឱ្យវាស៊ីបន្លែស្រស់ឱ្យបានច្រើន។ ត្រូវធ្វើយ៉ាងណាឱ្យមេជ្រូកធ្វើចលនាឱ្យបានច្រើនដើម្បីងាយស្រួលនៅពេលបង្កើតកូន។ ទ្រុងត្រូវមានពន្លឺគ្រប់គ្រាន់ និងត្រូវធ្វើអនាម័យឱ្យបានស្អាត និងស្ងួតជានិច្ច។ យើងត្រូវបង្ហាត់ជ្រូកឱ្យវាជុះអាចម៍ និងជុះនោមឱ្យត្រូវកន្លែង ព្រោះទំលាប់នេះយើងអាចរក្សាទ្រុងឱ្យបានស្អាតនៅពេលបង្កើតកូន។ ត្រូវពិនិត្យ និងតាមដានការរកឈ្មោលរបស់មេជ្រូកឱ្យច្បាស់លាស់ដើម្បីងាយស្រួលក្នុងការបង្កាត់ពូជ។ មុនពេលបង្កាត់ត្រូវពិនិត្យមើលសុខភាពរបស់វា ដើម្បីបំប៉នចំណី និងធ្វើការព្យាបាល។





## ៣.១.២.ការបង្កាត់

មេជ្រូកក្រមុំនៅពេលពេញវ័យ និងនៅពេលរកឈ្មោលវាអាចបង្ហាញសញ្ញារកឈ្មោលឱ្យយើងបានដឹង តាំងពីវាមានអាយុចាប់ពី ៥ខែកន្លះទៅ៦ខែកន្លះមកម្លេះ ប៉ុន្តែយើងមិនត្រូវ ធ្វើការបង្កាត់នៅពេលនេះទេ ព្រោះប្រសិនបើធ្វើការបង្កាត់ពេលនោះគឺមិនទទួលបានលទ្ធផលល្អឡើយ ព្រោះអត្រាផ្តល់កូនតិច ធ្វើឱ្យមេជ្រូកជួបនូវបញ្ហានៅពេលកើតកូន កូនមានលក្ខណៈខុសពីធម្មតា និងអត្រាងាប់ខ្ពស់។ ដូច្នេះយកល្អចាំបាច់ត្រូវរងចាំរហូត ដល់មេជ្រូកនោះរកឈ្មោលនៅលើកទី៣ ឬទី៤សិន គឺត្រូវ នឹង អាយុប្រហែលប្រមាណពី ៨ខែ ទៅ៩ខែ ធ្វើការបង្កាត់ទើបជាការល្អ។





- **រយៈពេលនៃការរកឈ្មោល**

មេជ្រូកអនុញ្ញាតឱ្យឈ្មោលឡើងពាក់តែនៅពេលវារកឈ្មោលតែប៉ុណ្ណោះ។ មេជ្រូកពេញវ័យដែលមិនទាន់បានដាក់បា(ដោយឈ្មោល) មិនទាន់ផើម មិនទាន់បានបំបៅកូនវាតែងតែរកឈ្មោលក្នុងកំឡុងពេលរៀងរាល់៣អាទិត្យម្តង(២១ថ្ងៃ)និងមានរយៈពេលប្រែប្រួលពី១ទៅ៥ថ្ងៃ អាស្រ័យទៅតាមប្រភេទពូជ

និងអាយុមេជ្រូក ក្មេង ឬចាស់។ រយៈពេលនៃការរកឈ្មោលរបស់មេជ្រូកក្នុងស្រុកពី ៣ ទៅ ៤ថ្ងៃ ចំពោះជ្រូកនាំចូលដូចជា ពូជជ្រូកយ៉កសៀរ ឡេនដ្រីស និងឌុយរ៉ុក រយៈពេលនៃការរកឈ្មោលរបស់វាពី ២ ទៅ៣ថ្ងៃ។ ប៉ុន្តែជាទូទៅការរកឈ្មោលរបស់មេជ្រូកមានរយៈពេល៣ថ្ងៃ។

### • សញ្ញានៃការរកឈ្មោល

មេជ្រូករកឈ្មោលបានបង្ហាញសញ្ញាដូចតទៅ៖

- យោនីរបស់វាឡើងពណ៌ក្រហម និងហើម
- មេជ្រូកមិនសូវស៊ីចំណី(ស៊ីចំណីតិច)
- មិនសូវដេក វាស្រែកថ្ងូរ ស្រែកឡូឡា
- ឡើងពាក់ជ្រូកផ្សេងៗទៀត។

ម្យ៉ាងទៀតដើម្បីបញ្ជាក់ឱ្យច្បាស់អំពីការរកឈ្មោលរបស់មេជ្រូកគឺធ្វើយ៉ាងណាឱ្យមានវត្តមានរបស់ជ្រូកបានៅទីនោះវានឹងបង្ហាញពីសញ្ញានៃការរកឈ្មោលហ្មែយើងបានដឹងដោយមេជ្រូកនោះដើរមកជិតនឹងឡើងពាក់ជ្រូកបា ឬឱ្យជ្រូកបានោះឡើងពាក់វាតែម្តង។ ប្រសិនបើអវត្តមានជ្រូកបាអ្នកចិញ្ចឹមអាចធ្វើការសាកល្បង ដោយចូលទៅជិតមេជ្រូកយ៉ាងស្ងៀមស្ងាត់រួចយកដៃទាំងពីរ សង្កត់លើត្រគៀករបស់វា បើមេជ្រូកនោះរកឈ្មោល ពិតប្រាកដវានឹងនៅស្ងៀម ហើយអ្នកចិញ្ចឹមអាចឡើងជិះអង្គុយពីលើខ្នងវាបានដោយគ្មានបញ្ហាអ្វោះឡើយ។




### • ពេលវេលានៃការដាក់ឈ្មោល

ការដាក់ឈ្មោលមេជ្រូកគួរគប្បីធ្វើឡើងនៅពេលព្រឹកព្រលឹម ឬពេលល្ងាចមុនពេលដាក់ចំណីឱ្យជ្រូកស៊ី។ កន្លែងសម្រាប់ដាក់ឈ្មោល(ដាក់បា)ត្រូវមានសភាពស្ងប់ស្ងាត់ និងរាបស្មើ។ ក្រោយពេលដាក់ឈ្មោលរួចអ្នកចិញ្ចឹម ឬម្ចាស់ជ្រូកមិនត្រូវងូតទឹក ឬឱ្យជ្រូកដេកក្នុងភក់ជ្រាំនោះទេ ព្រោះវាអាចបណ្តាលឱ្យមេជ្រូកគ្មានកូន ឬកូនតិច ឬអាចមានជំងឺឆ្លងផ្សេងៗកើតមានលើជ្រូក គប្បីដាក់មេជ្រូកឱ្យនៅក្នុងទ្រុងដោយឡែកតែឯង ចៀសវាង

កុំឱ្យមេជ្រូកឡើងពាក់គ្នា ជាន់គ្នា ឬខាំគ្នាដែលបណ្ដាលឱ្យមានកូនតិច ឬរលូតកូន។ ម្យ៉ាងទៀតនៅពេលអាកាសធាតុក្ដៅក៏អាចបណ្ដាលឱ្យមេជ្រូកមានកូនតិចផងដែរ។ ការដាក់ឈ្មោលដែលផ្ដល់កូនបានច្រើន និងកូនថ្លោសល្អ អ្នកចិញ្ចឹមគួរតែប្រើដាក់ឈ្មោលដល់មេជ្រូកដែលត្រូវដាក់នោះឱ្យបាន២ដង គឺលើកទី១ នៅ ពេលល្ងាចថ្ងៃទី២នៃការរកឈ្មោលរបស់វា និងលើកទី២ នៅពេលព្រឹកថ្ងៃទី៣នៃការរកឈ្មោលរបស់វា។ ម្យ៉ាងទៀតប្រសិនបើពុំអាចដាក់ឈ្មោល(ដាក់បា) បាន២ដងទេ អ្នកចិញ្ចឹមត្រូវដាក់ឈ្មោល(ដាក់បា) នៅក្នុងកំឡុងពេល២៤ទៅ៣០ម៉ោងក្រោយពេលមេជ្រូកចាប់ផ្ដើមរកឈ្មោល។





## • ការបង្កាត់ជាន់ឈាម

មេ និងបាជ្រូកដែលមានឪពុកម្ដាយតែមួយ វាមានឈាមដូចគ្នា។ ការបង្កាត់ជាន់ឈាមនាំឱ្យមានកូនតិច កូនកើតមកមិនធម្មតា ឬងាប់ ការលូតលាស់របស់កូនខ្សោយ និងងាយទទួលជំងឺឆ្លងផ្សេងៗ។

## ៣.១.៣- ការផើមរបស់មេជ្រូក

ក្រោយពេលដាក់ឈ្មោល(បា)បាន២១ថ្ងៃ(៣អាទិត្យ) ប្រសិនបើអ្នកចិញ្ចឹម ឬម្ចាស់សង្កេតឃើញថាមេជ្រូកឈប់រកឈ្មោលទៀត មានន័យថាមេជ្រូកនោះនឹងផើមហើយ។ ប៉ុន្តែប្រសិនបើក្រោយពេលដាក់ឈ្មោល២១ថ្ងៃ(៣អាទិត្យ)មេជ្រូកនឹងរកឈ្មោលឡើងវិញមានន័យថាមេជ្រូកមិនបានផើមនេះទេអ្នកចិញ្ចឹមឬម្ចាស់ត្រូវធ្វើការដាក់ឈ្មោល(បា)ឡើងវិញ។ ប៉ុន្តែយើងត្រូវពិនិត្យលើការលើការមិនរកឈ្មោល និងការដាក់ឈ្មោលមិនជាប់(ផើម)នេះ ព្រោះវាមានកត្តាជាច្រើនដែលធ្វើឱ្យជួបនូវបញ្ហាមួយចំនួនដូចជា កត្តាជំងឺ ការផ្ដល់ចំណីមិនត្រឹមត្រូវ ចំណីមិនមានគុណភាព ការថែទាំមិនបានដឹតដល់(មិនបានល្អ) ផងដែរ។ ម្យ៉ាងទៀតគេអាចសម្គាល់បានថា មេជ្រូកមានកូនបានតាមរយៈការស៊ីចំណី និងដេកច្រើន រោមនិងស្បែកមានសភាពកាន់តែរលោងពីមួយថ្ងៃទៅមួយថ្ងៃផងខ្លួនរីកធំ មានចរិកស្លូតបូត មានដំណើរមើលទៅធ្ងន់ដោះទាំងពីរជួររបស់មេជ្រូកឡើងតឹង ហើយរីកធំខុសពីដោះធម្មតា។ ក្នុងកំឡុងពេល២ខែក្រោយពីដោយ

ឈ្មោល ឬ ដាក់ ឈ្មោល(បា) រួចយើងសង្កេតឃើញថា ពោះរបស់មេជ្រូកឡើងធំច្បាស់។ រយៈពេលផើម ឬពរពោះរបស់ មេ ជ្រូកមានរយៈពេលគិតជាមធ្យមគឺ១១៤ថ្ងៃ វា ស្មើនឹង៣ខែ ៣អាទិត្យ និង៣ថ្ងៃ។





## ៣.១.៤- ការថែទាំមេជ្រូកក្នុងរយៈពេលផើម

ក្រោយពីដាក់ឈ្មោល(បា)រួច ត្រូវបណ្តើញមេជ្រូកឱ្យដើរដោយថ្នមៗបញ្ចូលទៅក្នុងទ្រុង។ ហាមដាក់មេជ្រូកនៅក្នុងទ្រុងចង្អៀត ហាមទាត់ធាក់ ឬបណ្តេញមេជ្រូកឱ្យវារត់ ព្រោះវាបណ្តាលឱ្យទឹកមេជីវិតឈ្មោល (ទឹកកាម)អាចហូរចេញមកក្រៅវិញ និងបណ្តាលឱ្យរលូតកូន។ អ្នកចិញ្ចឹម ឬម្ចាស់សត្វត្រូវធ្វើយ៉ាងណាឱ្យមេជ្រូកបានធ្វើចលនា ជាពិសេសនៅពេលព្រឹកព្រលឹមត្រជាក់ក្នុងទីធ្លារាបស្មើ។ នៅពេលមេជ្រូកជិតដល់ពេលកើតត្រូវបន្ថយការធ្វើចលនារបស់មេជ្រូកកុំឱ្យកូនក្នុងពោះធំពេកនាំឱ្យវាពិបាកកើត។ ត្រូវផ្តល់ចំណី និងទឹកដែលមានអនាម័យជានិច្ចដល់មេជ្រូក។





## ៣.១.៥- ការបង្កើតកូន

ការត្រៀមលក្ខណៈមុនពេលមេជ្រូកកើតគឺ១០ថ្ងៃមុនពេលមេជ្រូកកើតកូន ហើយម្ចាស់ ឬអ្នកចិញ្ចឹម ត្រូវរៀបចំទ្រុង ឬកន្លែងសម្រាប់ឱ្យមេជ្រូកកើតកូនឱ្យមានលក្ខណៈស្អាត ស្ងួតគ្មានមេរោគ មានខ្យល់អាកាសចេញចូលបានល្អមានពន្លឺគ្រប់គ្រាន់ និងមានសភាពស្ងប់ស្ងាត់ បាតទ្រុងត្រូវក្រាលកំរាលដោយប្រើប្រាស់ចំបើង ឬអង្កាមស្ងួតល្អ។

- **សញ្ញាបញ្ជាក់ថាមេជ្រូកជិតកើតកូនៈ**

នៅពេលមេជ្រូកជិតដល់ពេលកើតគេសង្កេតឃើញថា ដោះរបស់ទាំងពីរជួរឡើងធំពណ៌ក្រហម។ ម្យ៉ាងទៀត ប្រសិនបើគេធ្វើការច្របាច់ដោះរបស់វា គេនឹងឃើញមានចេញទឹកដោះពណ៌ស ឬពណ៌ថ្លាចេញពីដោះពេល នោះមេជ្រូកនៅមិនស្ងៀម វាមានលក្ខណៈតប់ប្រមល់ ខាំករកេររបស់របរផ្សេងៗនៅជុំវិញខ្លួនរបស់វា។ បន្ទាប់មកមេជ្រូកបានយកជើងមុខរបស់វាកាយដី ខាំចំបើង ស្មៅក្នុងទ្រុង ឈ្មុលទៅគៀនជញ្ជាំង (កាច់សំបុក) រួចមេជ្រូកនៅស្ងៀមស្ងាត់។ មុនពេលកើតកូនទី១ មកបន្តិច គេសង្កេតឃើញមានហូរចេញនៅទឹករំអិលខាប់ៗមានលាយឈាម។ តាមធម្មតាមេជ្រូកភាគច្រើនតែងតែកើតកូននៅពេលល្ងាច ឬយប់។ ចំពោះកូនជ្រូកអាចកើតចេញក្បាល ឬកន្ទុយមកមុន ហើយកូនជ្រូកនីមួយៗកើតចេញមកក្រៅរៀងរាល់១៥-២០ នាទី ម្តង។ ជាទូទៅរយៈពេលសរុបនៃការកើតកូនរបស់មេជ្រូកមានការប្រែប្រួលប្រមាណពី២ ទៅ ៦ ម៉ោង។ នៅពេលកូនជ្រូកកើតចេញមកច្រើនវាបានធ្វើឱ្យមានការរហែកស្រោម(សុក)ដោយខ្លួនឯងទើបចេញបកក្រៅ ហើយជួនកាលវាក៏អាចកើតចេញមកក្រៅទាំងស្រោម(សុក)ផងដែរ។ ហេតុដូចនេះនៅពេលមេជ្រូកកើតកូន ម្ចាស់សត្វ ឬអ្នកចិញ្ចឹមត្រូវ នៅពិនិត្យមើលវារហូត ដើម្បីជួយជូតមាត់ ច្រមុះរបស់កូនទើបកើតមកដោយប្រើក្រណាត់ស្ងួតធ្វើយ៉ាងណាកុំឱ្យកូនជ្រូកស្ទះដង្ហើម។ ជាការប្រសើរណាស់ នៅពេលមេជ្រូកកើតកូនដែលម្ចាស់នៅក្បែរមេជ្រូករហូតដល់ពេលកូនកើតចេញមកអស់ ព្រោះនេះជាតួនាទីដែលម្ចាស់ត្រូវធ្វើគឺ ត្រូវជូតសម្អាតកូនជ្រូកមួយក្បាលម្តងៗ រួចដាក់វាឱ្យនៅ កន្លែងស្អាត ស្ងួតល្អរហូតដល់អស់កូន។ កាលណាខ្លួនកូនជ្រូកស្ងួតហើយ ម្ចាស់ត្រូវចាប់កូនជ្រូកឱ្យបៅដោះមេ។





### ❖ ផលប្រយោជន៍នៃការចាំឃ្លាំមើលមេជ្រូកក្នុងកំឡុងពេលកើតកូន

នៅពេលមេជ្រូកកើតកូន ការជួយសង្គ្រោះកូនជ្រូកជាការសំខាន់ណាស់ពីការស្លាប់ដោយថប់ដង្ហើម ព្រោះមេជ្រូកមិនអាចលឧសំអាតខ្លួនដូចសត្វចិញ្ចឹមដ៏ទៃទៀតទេ។ ហេតុដូច្នេះនៅពេលកូនជ្រូកកើតមក ម្ចាស់សត្វត្រូវតែជូតសំអាតខ្លួន កាត់ទងផ្ចិត(ទងផ្ចិត)រួចចងទងផ្ចិត(ទងផ្ចិត)ឱ្យកូនជ្រូក និងរាំងមេជ្រូកកុំឱ្យដេកសង្កត់ ឬជាន់កូននៅក្នុងរយៈពេលកើតកូន ព្រោះមេជ្រូកខ្លះពេលកើតកូនតែងតែប្រែខ្លួន និងស្ទុះក្រោកឈរដែលបណ្តាលឱ្យវាអាចជាន់កូន និងដេកសង្កត់កូននៅពេលកំពុងបង្កើតកូននោះ។ ម្យ៉ាងទៀត នៅពេលមេជ្រូកកើតកូន ម្ចាស់សត្វត្រូវនៅជិតដើម្បីជួយសង្គ្រោះមេ និងកូនក្នុងករណីកើតពិបាក កើតមិនរួច ឬកើតក្នុងរយៈពេលវែង(យូរ) និងបង្ការកុំឱ្យមេជ្រូកស៊ីកូនឯង ឬស៊ីសុក ព្រោះធម្មតាសុកធ្លាក់មកក្រៅជាមួយកូននៅពេលកើត ហើយបើមិន។ ដូច្នេះទេ វានឹងធ្លាក់មកក្រៅនៅកន្លះម៉ោងក្រោយ ឬអាចអូសបន្លាយពេលដល់២ម៉ោងក្រោយកូនរួច។ ប្រសិនបើសុកមិនធ្លាក់តាមការកំណត់ទេ យើងត្រូវ ចាក់ថ្នាំអុកស៊ីតូស៊ីន និងត្រូវដាក់ឱ្យកូនវាបៅ។ ហេតុដូចនេះម្ចាស់សត្វ ចាំបាច់ត្រូវរាប់ចំនួនសុកដែលធ្លាក់មក ថាតើគ្រប់តាមចំនួនកូនដែលបានកើតមកហើយ ឬនៅ ប្រសិនបើសុកធ្លាក់មកគ្រប់ចំនួនដែលកូនបានកើតមកមានន័យថាសុកបានធ្លាក់ចេញមកក្រៅអស់។









### ❖ របៀបសន្មត់កាលបរិច្ឆេតនៃការកើតកូន

កាលបរិច្ឆេទសន្មត់នៃការកើតកូន= កាលបរិច្ឆេទនៃការរដោយឈ្មោល + ១១៦ថ្ងៃ។

## ៣.១.៦- ការបំបៅកូន

កូនជ្រូកមុនពេលផ្តាច់ដោះ ជីវិតរស់នៅរបស់វាគឺពឹងផ្អែកទាំងស្រុងទៅលើទឹកដោះម្តាយ(មេ)។ ដូចនេះក្រោយពេលកូនជ្រូកកើតមក ម្ចាស់ត្រូវធ្វើយ៉ាងណាឱ្យវាបៅដោះមេឱ្យបានច្រើន ព្រោះទឹកដោះដំបូងរបស់មេមាន តែក្នុងរយៈពេលពី ២-៣ថ្ងៃ បន្ទាប់ពីកូនរួចប៉ុណ្ណោះ។ ចំពោះទឹកដោះដំបូងនេះ គឺវាមានគុណភាពខ្ពស់ជាងទឹកដោះ ធម្មតាសម្រាប់ទ្រទ្រង់ជីវិត ព្រមទាំងមានអង់ទីគ័រជួយឱ្យកូនជ្រូកអាចប្រឆាំងនឹងមេរោគបានច្រើនប្រភេទទៀតផង។

ម្យ៉ាងទៀត ទឹកដោះដំបូងក៏ជួយបង្កើនថាមពលដល់កូនជ្រូកក្នុងការទប់ទល់ភាពត្រជាក់ផងដែរ ប៉ុន្តែទឹកដោះរបស់មេជ្រូកនឹងចុះថយជាលំដាប់ ចាប់ពីអាទិត្យទី៣ទៅ។ ផ្ទុយទៅវិញសេចក្តីត្រូវ ការរបស់កូនជ្រូកកាន់តែខ្ពស់នៅពេលនោះជាតិដែកដែលស្តុកនៅក្នុងថ្លើមរបស់កូននៅក្នុងរយៈពេលដើម(កូននៅក្នុងពោះរបស់មេ)ត្រូវខ្វះខាត ហើយទឹកដោះមេក៏មិនគ្រប់គ្រាន់នាំឱ្យកូនជួបប្រទះនូវជំងឺស្លេកស្លាំងរាគរូស និងកូនជ្រូកចុះស្គម។ គេច្រើនជួបប្រទះបញ្ហានេះ ចំពោះជ្រូកចិញ្ចឹមមិនឱ្យ ប៉ះដី (ដោយធ្វើទ្រុងខ្ពស់ផុតដី) ហើយផ្តល់ចំណីមិនគ្រប់គ្រាន់តាមតម្រូវការរបស់ជ្រូក។





ខាងក្រោមនេះជាគំនូសតាងបង្ហាញអំពីសេចក្តីត្រូវការរបស់កូនជ្រូក និងការផ្តល់ទឹកដោះរបស់ មេជ្រូក




ដើម្បីការពារជំងឺខ្វះឈាម គេអាចផ្តល់ជាតិដែកដល់កូនជ្រូកដោយចាក់ឬឱ្យលេបចាប់ពីកូនជ្រូកមានអាយុ៣-៧ថ្ងៃក្រោយពេលកើតជាការប្រសើរណាស់ដែលកូនជ្រូកអាចចេះស៊ីចំណីបានល្អនៅអាយុ២១ថ្ងៃ។ ដូចនេះ ចាំបាច់ត្រូវបង្រៀនកូនជ្រូកឱ្យចេះស៊ីចំណីចាប់តាំងពីវាមានអាយុ ៧-១០ថ្ងៃ ហើយចំណីដែលឱ្យវាស៊ីនោះ ជាចំណីដែលងាយរលាយ ដូចជា បបរអង្ករ ម្សៅទឹកដោះ។ល។ ព្រោះប្រដាប់រំលាយអាហាររបស់កូនជ្រូកនៅខ្សោយមិនអាចរំលាយចំណីរឹងបាន និងមានលទ្ធភាពប្រឆាំងមេរោគនៅខ្សោយ។ ការបង្ហាត់កូនជ្រូកឱ្យចេះស៊ីចំណីនេះគឺវាមានសារៈសំខាន់ណាស់សម្រាប់នៅពេលត្រូវយើងធ្វើការផ្តាច់ដោះ។





## ៣.១.៧- ការចិញ្ចឹមកូនជ្រូកកំព្រា ឬកូនជ្រូកកើតលើសពីចំនួនដោះមេ

ការចិញ្ចឹមកូនជ្រូកកំព្រា ឬកូនជ្រូកកើតលើសពីចំនួនដោះមេ គឺជាបញ្ហាលំបាកសម្រាប់អ្នកចិញ្ចឹម ឬម្ចាស់សត្វ។ ដើម្បីចិញ្ចឹមកូនជ្រូកកំព្រា ឬកូនជ្រូកកើតលើសពីចំនួនដោះមេនោះ គឺគេអាចអនុវត្តបានក្នុងការចិញ្ចឹមតាម២របៀបដូចតទៅ៖

### ១-ការចិញ្ចឹមកូនជ្រូករបៀបផ្ញើរ

វិធីនេះគេអនុវត្តតែក្នុងតំបន់ដែលមានការចិញ្ចឹមមេជ្រូកច្រើន ដោយគេយកចំនួនកូនជ្រូកដែលលើសទាំងនោះ ទៅដាក់ជាមួយមេជ្រូកណាដែលមានចំនួនកូនតិចជាងចំនួនដោះរបស់មេ ហើយមេជ្រូកបានកើតកូនក្នុងពេលប្រហាក់ប្រហែលគ្នា(ច្រើនបំផុតរយៈពេលខុសគ្នាប្រមាណប្រហែលពី២-៣ថ្ងៃប៉ុណ្ណោះ)។ ប៉ុន្តែមុនពេលដាក់បញ្ចូលជាមួយមេជ្រូកផ្សេងដែលកើតកូនបានប្រមាណ២-៣ថ្ងៃនោះយើងត្រូវធ្វើយ៉ាងណាឱ្យកូនជ្រូកទាំងនោះ បានបៅដោះមេវាយ៉ាងតិចក៏ ១ថ្ងៃដំបូងដែរទើបយើងធ្វើការបំបែកវាដាក់បញ្ចូលជាមួយមេផ្សេងនោះ។ ម្យ៉ាងទៀត ដើម្បីធ្វើយ៉ាងណាកុំឱ្យមេជ្រូកដែលយើងយកកូនជ្រូកដ៏ទៃទៅផ្ញើរជាមួយដឹងក្លិនមិនមែនជាកូនរបស់វាគឺគេត្រូវ ដាក់បញ្ចូលគ្នានៅពេលយប់ដើម្បីចៀសវាងកុំឱ្យកូនជ្រូកខាំគ្នា ឬយើងអាចលាបកូនជ្រូកទាំងអស់(ទាំងកូនបង្កើត និងកូនជ្រូកដែលត្រូវដាក់ផ្ញើ) ដោយប្រេងកាត ឬជាតិប្រេងផ្សេងៗទៀតដែលអាចធ្វើទៅបាន ដើម្បីឱ្យកូនជ្រូកមានក្លិនដូចគ្នា។ ប្រសិនបើ យើងមិនបានធ្វើដូចនេះទេ មេជ្រូកអាចនឹងខាំកូនជ្រូកដែលបានដាក់ផ្ញើជាមួយនោះ និងមិនព្រមឱ្យកូន ជ្រូកទាំងនោះបៅដោះវាឡើយ។





### ២-ការបំបៅកូនជ្រូកដោយសិប្បនិម្មិត

ការបំបៅកូនជ្រូកដោយសប្បនិម្មិតជាតួនាទីរបស់ម្ចាស់សត្វ ព្រោះក្នុងរយៈពេល២ថ្ងៃដំបូងអ្នកចិញ្ចឹមឬម្ចាស់សត្វ ត្រូវបំបៅកូនជ្រូកក្នុងចន្លោះពេលមួយទៀងទាត់៥ដងក្នុងមួយថ្ងៃ។ នៅថ្ងៃទី៣ និងថ្ងៃទី៤ ត្រូវបំបៅដោះកូនជ្រូកឱ្យបាន៤ដងក្នុងមួយថ្ងៃ។ ចាប់ពីថ្ងៃទី៥ទៅត្រូវឱ្យកូនជ្រូកបៅដោះ៣ដងក្នុងមួយថ្ងៃរហូតដល់វាមានអាយុបាន៣អាទិត្យ(ពេលវាអាចស៊ីចំណីបាន)។ក្រោយពីកូនជ្រូកមានអាយុ៣អាទិត្យយើងអាចបញ្ឈប់ការបំបៅដោះដោយបន្តឱ្យវាស៊ីបបរលាយ ជាមួយស្ករឡែមៗផ្សំនឹងចំណីដែលអាចស៊ីបានរហូតដល់អាយុ ៣៥ថ្ងៃ ទើបផ្តល់ចំណីជារបៀបកូនជ្រូកផ្តាច់ដោះវិញ។ អ្នកចិញ្ចឹម ឬម្ចាស់សត្វត្រូវបំបៅកូនដោយប្រើទឹកដោះគោឬទឹកដោះពពែស្រស់។ ហាមលាយជាមួយទឹក ព្រោះទឹកដោះមេជ្រូកមានកំហាប់ខ្ពស់ណាស់។





## ៣.១.៨- ការផ្តាច់ដោះកូនជ្រូក

ការផ្តាច់ដោះកូនជ្រូកដោយធ្វើឡើងមាន ២របៀបគឺ៖

### ១)ការផ្តាច់ដោះកូនជ្រូកដោយសន្សឹមៗ

ការផ្តាច់ដោះកូនជ្រូកតាមរបៀបនេះ គឺធ្វើឡើងដោយកាត់បន្ថយចំនួននៃការបំបៅដោះកូនពីមេដោយបំបែកកូនចេញពីមេឱ្យនៅដោយឡែកជាបណ្តោះអាសន្នក្នុងរយៈពេលពី១-៨ម៉ោងក្នុងមួយថ្ងៃ។ គេអាចអនុវត្តបាន នៅពេលកូនជ្រូកមានអាយុបាន១ខែ។ ការផ្តាច់ដោះកូនជ្រូកតាមរបៀបនេះគឺពុំមានផលអាក្រក់ដល់សុខភាពរបស់កូនជ្រូក និងមិនបណ្តាលឱ្យមេជ្រូកមានជំងឺលាសដោះនោះទេ។ ម្ចាស់សត្វត្រូវបំបែកមេជ្រូកចេញពីកូនទៅដាក់ទ្រុងផ្សេង ឬដាក់នៅកន្លែងណាមួយដោយមិនឱ្យមើលឃើញគ្នាបាន។ យើងអាចផ្តាច់ដោះកូនជ្រូកណាដែលថ្លោសជាងគេ មុនជាបណ្តើៗបាន។

### ២)ការផ្តាច់ដោះកូនជ្រូកភ្លាមៗ

ការផ្តាច់ដោះកូនជ្រូកភ្លាមៗ គឺគេយកមេជ្រូក ឬកូនចេញពីគ្នា និងបញ្ឈប់ការបំបៅដោះកូនទាំងស្រុងភ្លាមៗការផ្តាច់ដោះបែបនេះត្រូវធ្វើឡើងដោយមានការប្រុងប្រយ័ត្ន។ អាយុកូនជ្រូកដែលត្រូវធ្វើការផ្តាច់

ដោះគឺ មិនឱ្យតិចជាង៣៥ថ្ងៃនោះឡើយ។ ប្រសិនបើ ការផ្ដាច់ដោះកូនជ្រូកមិនអនុវត្តឱ្យបានត្រឹមត្រូវធ្វើឱ្យកូនបាក់ទឹកដោះ និងបណ្ដាលឱ្យកូនជួបប្រទះនូវជំងឺស្លេកស្លាំង រាគរូស ចុះស្គម និងពិបាកក្នុងការចិញ្ចឹម។ ក្នុងកំឡុងពេល៥ថ្ងៃ មុនពេលផ្ដាច់ដោះមេជ្រូកមិនឱ្យកូនបៅ ចាំបាច់ត្រូវបន្ថយចំណីដល់មេជ្រូកបន្តិចម្ដងៗ ដើម្បីកុំឱ្យមេជ្រូកមានទឹកដោះច្រើនពេកដែលជាហេតុនាំឱ្យមេជ្រូកកើតជំងឺលាសដោះ។ ក្រោយពេលផ្ដាច់ដោះម្ចាស់សត្វត្រូវពិនិត្យមើលដោះមេជ្រូកជាប្រចាំ បើមានជំងឺត្រូវធ្វើការព្យាបាលជាបន្ទាន់។

## ៣.១.៩- ការវិលត្រឡប់រកឈ្មោលរបស់មេជ្រូកក្រោយពេលផ្ដាច់ដោះ

ជាធម្មតាមេជ្រូកអាចរកឈ្មោលឡើងវិញនៅចន្លោះពេលពី១-២អាទិត្យក្រោយពេលផ្ដាច់ដោះ។ ប៉ុន្តែវាក៏អាចឆាប់រកឈ្មោលជាងនេះដែរ ប្រសិនបើគេបំប៉ន និងថែទាំបានល្អ។ ម្យ៉ាងទៀតប្រសិនបើមេជ្រូកមិនរកឈ្មោលក្នុងរយៈពល១៥ថ្ងៃក្រោយពេលផ្ដាច់ដោះគឺអាចបណ្ដាលមកពីៈ

- រយៈពេលបំបៅកូនវែងពេក
- ការបំបៅកូនកាន់តែប្រើរយៈពេលខ្លីកាលណាធ្វើឱ្យមេជ្រូកនឹងឆាប់រកឈ្មោលកាន់តែលឿន
- ការចិញ្ចឹមក្នុងល័ក្ខខ័ណ្ឌមិនល្អ កង្វះអនាម័យទូទៅ
- មេជ្រូកស្គមពេកដោយមានជំងឺឆ្លងផ្សេងៗ
- ការផ្ដល់ចំណីមិនត្រឹមត្រូវៈក្រោយផ្ដាច់ដោះមិនបានបន្ថយចំណីដល់មេជ្រូកតែបែរជាបន្ថែមចំណីដល់មេជ្រូកទៅវិញ។

**ដើម្បីឱ្យមេជ្រូកឆាប់រកឈ្មោលក្រោយពេលផ្ដាច់ដោះ**

- បន្ថយចំណីមេជ្រូកបន្តិចម្ដងៗរយៈពេល ៥ថ្ងៃមុនពេលផ្ដាច់ដោះ
- បង្អត់ចំណីនិងទឹកដល់មេជ្រូកនៅថ្ងៃផ្ដាច់ដោះ និង១ថ្ងៃបន្ទាប់ក្រោយពេលផ្ដាច់ដោះ។ បន្ទាប់មកត្រូវឱ្យចំណីដល់មេជ្រូកស៊ីដោយសេរី
- អនុវត្តការផ្ដាច់ដោះមេជ្រូកភ្លាមៗប្រសើរជាងការអនុវត្តការផ្ដាច់ដោះសន្សឹមៗដោយយកមេជ្រូកចេញពីកូនរបស់វា រួចយកដាក់ក្នុងទ្រុងក្បែរជ្រូកបាដើម្បីឱ្យវាឆាប់រកឈ្មោល
- ធ្វើការចាក់វីតាមីនអាដេអឺ(ADE)។

## ៣.១.១០- ការថែទាំ និងប្រើប្រាស់ជ្រូកបា

ត្រូវផ្ដល់ចំណីឱ្យជ្រូកបាឱ្យបានគ្រប់គ្រាន់ទៅតាមបច្ចេកទេស។ ជ្រូកបាមិនត្រូវឱ្យធាត់ពេកទេ ឬស្គម ពេកទេ ព្រោះនៅពេលជ្រូកបាមានសភាពស្គមពេកធ្វើឱ្យមិនអាចពាក់មេបានល្អ។ ចំពោះជ្រូកបាដែលមានធាត់ពេកធ្វើឱ្យវាខ្ជិលល និងគុណភាពមេជីវិត(ទឹកកាម)ទាប។ នៅពេលដែលគ្មានជ្រូកមេឱ្យវាពាក់ទេ យើងត្រូវបំបែកជ្រូកបានោះពីជ្រូកដទៃទៀត។ ម្យ៉ាងទៀតប្រសិនបើយើងប្រើប្រាស់វាហួសកំលាំងអាចឱ្យវាបាត់ បង់សមត្ថភាពផលិតមេជីវិតបានល្អទេ។ ជាធម្មតាជ្រូកបាមួយក្បាលអាចធានាក្នុងការផ្ដល់កំណើតកូនបានល្អ សម្រាប់មេជ្រូកពី៣០-៤០ក្បាលប៉ុណ្ណោះ។ ចំពោះបាជ្រូកជំទង់ យើងមិនត្រូវចាប់បង្ខំឱ្យ វាឡើងពាក់មេនោះទេ ត្រូវបង្ហាត់មួយរយៈពេលគឺពី២-៤អាទិត្យ និងបន្ទាប់មកយើងត្រូវប្រើប្រាស់វា

ដោយសន្សឹមៗ។ កត្តាសំខាន់ ក្នុងការផ្តល់ឱ្យបាជ្រូកឡើងពាក់មេលើកដំបូង យើងត្រូវធ្វើការជ្រើសរើសមេជ្រូកណា ដែលមានមាឌ ប្រហាក់ ប្រហែល នឹងបាជ្រូកនោះ។

**តារាងចំនួនដងនៃការពាក់មេទៅតាមអាយុបាជ្រូក**

| អាយុបាជ្រូក | ចំនួនពាក់មេជ្រូកច្រើនបំផុត | | |
|---|---|---|---|
| | ក្នុង១ថ្ងៃ | ក្នុង១អាទិត្យ | ក្នុង១ខែ |
| អាយុក្រោម ៦ខែ | ០ | ០ | ០ |
| អាយុចាប់ពី ៦ខែដល់ ៩ខែ | ១ | ៤ | ១៥ |
| អាយុចាប់ពី ៩ខែដល់ ១២ខែ | ២ | ៨ | ២៥ |
| អាយុចាប់ពី ១២ខែឡើង | ៣ | ១២ | ៣៥ |

**ចំណាំ:** មិនគួរប្រើប្រាស់បាជ្រូកឱ្យលើសពី៤ឆ្នាំឡើយ ព្រោះវាកាចហើយមានទម្ងន់ធ្ងន់ពេក។

## ៣.២- ការថែទាំអនាម័យ និងសុខភាព

### ៣.២.១- ការធ្វើអនាម័យទីកន្លែងរស់នៅ

- **ទ្រុង:** ត្រូវបោសសំអាតលាមកឬជុសលាងទ្រុងឱ្យបានស្អាតល្អរៀងរាល់ព្រឹក និងល្ងាចជាពិសេសមុនពេលធ្វើការដាក់ចំណីឱ្យសត្វស៊ី។ ការធ្វើបែបនេះអាចទប់ស្កាត់ការរាលដាលនៃជំងឺឆ្លងពីសត្វមួយទៅសត្វមួយទៀត និងធ្វើឱ្យបរិស្ថាននៅក្នុង និងជុំវិញទ្រុងគ្មានក្លិន។

- **ស្នូកទឹក និងស្នូកចំណី:** ត្រូវលាងសំអាតស្នូកទឹក និងស្នូកចំណីឱ្យបានស្អាតល្អមុនពេលដាក់ចំណីឱ្យជ្រូកស៊ី ដើម្បីកាត់បន្ថយការឆ្លងជំងឺផ្សេងៗ។ ស្នូកទឹក និងស្នូកចំណី ត្រូវធ្វើយ៉ាងណាឱ្យវានៅនឹងមួយកន្លែង ដើម្បីជៀសវាងកុំឱ្យជ្រូកចាក់ទឹក និងចំណីចោល(ខ្ជះខ្ជាយ) ហើយយើងត្រូវដាក់ទឹកស្អាតឱ្យសត្វផឹកឱ្យបានគ្រប់គ្រាន់ និងជាប្រចាំនៅក្នុងទ្រុង ជាពិសេសនៅពេលថ្ងៃក្តៅ។





### ៣.២.២- ការធ្វើអនាម័យលើខ្លួនសត្វ

ត្រូវដុសលាងសំអាតខ្លួនសត្វឱ្យបានទៀងទាត់ គឺក្នុងមួយថ្ងៃឱ្យបានមួយដង គឺដោយយើងធ្វើឡើងនៅពេលថ្ងៃត្រង់ ដើម្បីកុំឱ្យជ្រូក មានសភាពកខ្វក់ដែលជាហេតុនាំឱ្យសត្វចុះខ្សោយកំលាំង និងឆាប់ទទួលរងនូវការឆ្លងជំងឺផ្សេងៗ។ ជាពិសេស អ្នកចិញ្ចឹម ឬម្ចាស់ជ្រូក អាចដឹងបាន ថានៅលើខ្លួនសត្វ មានរបួស ឬក៏អត់ ឬ សត្វមានសុខភាពល្អ ឬអត់ បានផងដែរ។ ចំពោះការងូតទឹកឱ្យសត្វគឺធ្វើឱ្យសត្វមានសេចក្តីសុខ និងធ្វើឱ្យសត្វមានការសប្បាយចិត្តផងដែរ។

### ៣.២.៣- ការធ្វើអនាម័យលើចំណីអាហារ និងទឹក

ចំណីដែលផ្តល់ឱ្យសត្វស៊ីត្រូវមានអនាម័យ គួរកុំផ្តល់ចំណីឱ្យសត្វស៊ីនូវចំណីណាដែលមានសភាពកខ្វក់ ជូរផ្អូម ឬធំក្លិនស្អុយរលួយ ព្រោះវាអាចផ្ទុកទៅដោយមេរោគដែលធ្វើឱ្យប៉ះពាល់ដល់សុខភាព និងផ្លូវរំលាយអាហាររបស់សត្វ។ ចំណែកការផ្តល់ទឹកដល់សត្វត្រូវតែស្អាតជានិច្ចហើយមិនត្រូវឱ្យសត្វដាក់ជើងរបស់វាក្នុងស្នូកទឹក និងស្នូកចំណីឡើយ។

## ៤- បញ្ហាកើតឡើងលើមេ និងបាជ្រូក

### បញ្ហាកើតឡើងចំពោះជ្រូកមេ

ការចិញ្ចឹមជ្រូកមេ តែងតែជួបប្រទះនូវបញ្ហាមួយចំនួនដូចជាៈ មេស៊ីកូន មេកើតកូនរួចមិនធ្លាក់សុក មេកូនតិច និងមេកើតកូនធំតូចមិនស្មើគ្នាជាដើម។

### ៤.១.១- មេជ្រូកស៊ីកូន

ចំពោះមេជ្រូកដែលស៊ីកូនគេតែងជួបប្រទះទៅលើមេជ្រូកចាស់ៗ។ កត្តាទាំងនេះបណ្តាលមកពីចំណីពុំមានគុណភាព(ខ្វះជាតិសាច់ ឬជាតិកាលស្យូមច្រើន) ឬបណ្តាលមកពីមេជ្រូកស្រេកឃ្លានខ្លាំងនៅពេលវាបង្កើតកូន និងជួនកាលអាចបណ្តាលមកពីមេជ្រូកពិបាកកើតកូន កូនខាំដោះមេដែលបណ្តាលឱ្យមេវាខឹង ឬ បណ្តាលមកពីមេជ្រូកស៊ីសុក បន្ទាប់មកវាស៊ីទាំងកូន។

- **ការការពារ**

នៅពេលមេជ្រូកបានកើតកូនរួច អ្នកចិញ្ចឹម ឬម្ចាស់សត្វធ្វើយ៉ាងណា ត្រូវថែទាំមេជ្រូកឱ្យបានល្អ ផ្តល់ចំណីដែលមានសារធាតុចិញ្ចឹមឱ្យបានគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព និងត្រូវផ្តល់ទឹកដល់មេជ្រូកផឹកឲ្យបានគ្រប់គ្រាន់ និងមានជាប្រចាំ។

- **ការព្យាបាល**

អ្នកចិញ្ចឹម ឬម្ចាស់សត្វ ត្រូវធ្វើយ៉ាងណាចាប់កូនជ្រូកចេញពីមេ កាលណាឃើញវាស៊ីកូន ត្រូវចាក់កាលស្យូមគ្លុយកូស (Gluconate de Calcium) ដោយយើងធ្វើការចាក់តាមសសៃដល់មេជ្រូក និងផ្តល់ចំណី និងទឹកឱ្យមេជ្រូកឱ្យបានគ្រប់គ្រាន់។ ម្យ៉ាងទៀតត្រូវបន្ថែមចំណីដែលសំបូរជាតិសាច់ ជាតិវីតាមីនដល់ មេជ្រូក និងកំណត់ម៉ោងពេលវេលាឱ្យបានច្បាស់លាស់សម្រាប់ឱ្យកូនបៅ។ នៅពេលណាមេជ្រូកឈប់ខាំកូន ទើបយើងធ្វើការលែង ឬបញ្ចូលកូនឱ្យទៅរស់នៅជាមួយមេរបស់វាវិញ។

## ៤.១.២ ជ្រូកមេកើតកូនហើយមិនធ្លាក់សុក

ជាធម្មតា សុកត្រូវធ្លាក់មកក្រៅអស់ក្នុងកំឡុងពេលពី៣-៤ម៉ោងបន្ទាប់ពីកូនកើតអស់ ប៉ុន្តែជួនកាល អាចរហូតដល់ពី៥-៦ម៉ោងក្រោយពេលកូនកើតអស់។

- **មូលហេតុ**
  - បណ្តាលមកពីមេជ្រូកចាស់ស្គមខ្លាំង ខ្សោយ ពិបាកកើតកូន ឬរយៈពេលកើតកូនយូរពេល
  - បណ្តាលមកពីកូននៅក្នុងពោះមានគ្រោះថ្នាក់ក្នុងពេលផើម (ការដឹកនាំការវាយដំ ឬដួល)
  - បណ្តាលមកពីមេមានជំងឺរលូតកូន
  - បណ្តាលមកពីចំណីមេជ្រូកនៅពេលផើមមិនគ្រប់គ្រាន់ ខ្វះជីវជាតិ ខ្វះជាតិកាលស្យូម ខ្វះជាតិអំបិល និងសារជាតុចិញ្ចឹមផ្សេងៗទៀត។

ដូច្នេះ អ្នកចិញ្ចឹមឬម្ចាស់សត្វត្រូវរងចាំពិនិត្យមើលការធ្លាក់សុករបស់មេជ្រូកក្រោយពេលកូនកើតរួច និងត្រូវពិនិត្យមើលចំនួនសុកគឺត្រូវតែគ្រប់នឹងចំនួនកូនដែលបានកើតមក។ ម្យ៉ាងទៀតចំពោះសុកដែលមិនធ្លាក់ចេញមកក្រៅវានឹងស្អុយរលួយនៅក្នុងស្បូនដែលបណ្តាលឱ្យរលាក់ស្បូនរបស់មេជ្រូកនោះ។

- **ការព្យាបាល**

ត្រូវប្រើប្រាស់ថ្នាំជំនួយដែលមានប្រសិទ្ធភាពក្នុងការជម្រុញការកន្ត្រាក់នៃសាច់ដុំស្បូនដើម្បីធ្វើយ៉ាងណាឱ្យសាច់ដុំស្បូនកន្ត្រាក់រុញសុកចេញមកក្រៅ។

## ៤.១.៣- មេជ្រូកកើតកូនតិច

- **មូលហេតុ**
  - បណ្តាលមកពីមេដាក់បាមិនត្រូវតាមពេលវេលា
  - បណ្តាលមកពីបាបាក់កំលាំងដោយសារបាត្រូវបានពាក់មេច្រើនពេក
  - បណ្តាលមកពីបាត្រូវបានសម្រាក់ ឬខានពាក់មេយូរថ្ងៃ
  - បណ្តាលមកពីមេជ្រូកស្គមពេកព្រោះចំណីមិនគ្រប់គ្រាន់ ជំងឺស្បូនរាំរៃ និងជំងឺបរាសិត
  - មេជ្រូកធាត់ពេក និងក៏អាចបណ្តាលមកពីពូជផងដែរ។

## ៤.១.៤- មេជ្រូកកើតកូនធំតូចមិនស្មើគ្នា

- **មូលហេតុ**
  - មេជ្រូកធ្វើចលនាបានតិច ព្រោះដោយការចិញ្ចឹមដាក់ក្នុងទ្រុងចង្អៀត
  - ស្បូនមេជ្រូកមានលក្ខណៈមិនធម្មតា មួយកំណាត់ធំ មួយកំណាត់តូច

- មេជ្រូកស៊ីចំណីរឹងខ្វះជាតិបន្លែស្រស់ ស្មៅ ផឹកទឹកកមិនគ្រប់គ្រាន់ បណ្ដាលឱ្យមេជ្រូកទល់លាមកស្បូនត្រូវពោះវៀនសង្កត់ជាកងៗបណ្ដាលឱ្យកូនក្នុងពោះលូតលាស់មិនស្មើគ្នា។

- **វិធានការការពារ**

ជាទូទៅ ម្ចាស់សត្វត្រូវស្វែងរកអំពីមូលហេតុដែលបណ្ដាលឱ្យមេជ្រូកកើតកូនមកមានលក្ខណៈធំតូច មិនស្មើគ្នា ដើម្បីបំបាត់មូលហេតុទាំងនេះធ្វើឱ្យកូនជ្រូកកើតមកមានលក្ខណៈធំស្មើគ្នា។

## ៤.១.៥- មេជ្រូកខ្វះទឹកដោះឱ្យកូនបៅ

- **មូលហេតុ**

- ចំណីដែលផ្ដល់ឱ្យមេជ្រូកខ្វះជាតិសាច់ ជាតិរ៉ែ ជាពិសេសជាតិកាលស្យូម ដើម្បីបង្កើតទឹកដោះ សម្រាប់ឱ្យកូនបៅ
- មេជ្រូកទល់លាមក ឬមានជំងឺផ្លូង ជម្ងឺរលាសដោះ និងជំងឺរលាកស្បូន
- ការចិញ្ចឹមមេជ្រូកដោយដាក់ក្នុងទ្រុងមានសភាពស្អុះស្អាប់ពេក មេជ្រូកមានសភាពភ័យខ្លាចខ្លាំងយើងអាចសង្កេតឃើញមេជ្រូកដែលខ្វះទឹកដោះនោះឱ្យកូនបៅតែមួយភ្លែតវាលាសដោះឈប់ឱ្យកូនបៅតទៅទៀត ធ្វើឱ្យកូនរបស់វាមានការស្រេកឃ្លានខ្លាំង ចុះស្គមបន្តិចម្ដងៗ ស្បែករបស់វាមានសភាពជ្រីវជ្រួញ ជូនកាលវាមានសភាពញាក់ញ័រដោយខ្វះជាតិស្ករ និងមេជ្រូកមានសភាពមួម៉ៅខាំកូនខ្លួនឯង។

- **វិធីការការពារ**

- ត្រូវធ្វើយ៉ាងណាកុំឱ្យមេជ្រូកទល់លាមក
- ការពារ និងព្យាបាលជំងឺលាសដោះ និងជំងឺរលាកស្បូនដល់មេជ្រូក
- ត្រូវចាក់ថ្នាំការពារជំងឺឱ្យគ្រប់មុខមុនពេលដាក់បា
- ត្រូវកែលំអទ្រុងចិញ្ចឹមឱ្យមានខ្យល់អាកាសចេញចូលឱ្យបានល្អ និងមានសភាពស្ងប់ស្ងាត់
- ត្រូវផ្ដល់ចំណីដែលមានជាតិសាច់ និងជាតិរ៉ែបន្ថែមឱ្យមេជ្រូក

## ៤.១.៦- បាជ្រូកបាត់បង់សមត្ថភាពបង្កាត់

- **មូលហេតុ**

កត្តាដែលបណ្ដាលឱ្យបាជ្រូកបាត់បង់ ឬអសមត្ថភាពក្នុងការបង្កាត់ពូជរួមមានៈ

- បណ្ដាលមកពីបាជ្រូកនោះធាត់ពេក ទ្រុងតូចចង្អៀត មិនឱ្យបានោះធ្វើចលនាបានច្រើន ឬការផ្ដល់ចំណីដល់បានោះសំបូរទៅដោយជាតិម្សៅដែលបណ្ដាលឱ្យបាចុកខ្លាញ់
- បណ្ដាលមកពីការចិញ្ចឹមបាជ្រូកនោះដោយដាក់ឱ្យរស់នៅតែឯងតាំងពីតូចធ្វើឱ្យបាជ្រូកមានភាពភ័យខ្លាចនៅពេលឃើញជ្រូកច្រើន
- ការផ្ដល់ចំណីពុំមានគុណភាព ចំណីមិនល្អ ខ្វះជីវជាតិ ក្រពេញភេទលូតលាស់មិនល្អ

- បណ្តាលមកពីបាជ្រូកនោះនៅក្មេងពេក ខ្លាចមេ ព្រោះធ្លាប់មេខាំឱ្យរបួស
- បណ្តាលមកពីបាជ្រូកធ្លាប់មានរបួសធ្ងន់ ឈឺឆ្អឹង ឈឺជើងមិនហ៊ានកំរើក
- បណ្តាលមកពីបាជ្រូកនោះកំលាំង ព្រោះបានពាក់មេក្នុងថ្ងៃមួយច្រើនពេក បណ្តាលមកពីដឹកបាជ្រូក ទៅធ្វើការបង្កាត់ផ្លូវឆ្ងាយបណ្តាលឱ្យហេវហត់ ប្លែកកន្លែង ចម្លែកមនុស្សដែលបណ្តាលឱ្យវាមានអារម្មណ៍មិនល្អ និងចាញ់ច្រាប
- បណ្តាលមកពីបានោះស្គមពេក មានសភាពខ្សោយ ព្រោះផ្តល់ចំណីមិនគ្រប់គ្រាន់ ឬកើតជំងឺពពួកបារាស៊ីតដូចជា ពពួកព្រូន អង្គែ គេនញ្ញាជាដើម។

## ៤.១.៧-បាជ្រូកផ្តល់កូនតិច

### ✚ ការចិញ្ចឹមសត្វ

កត្តាសំខាន់គឺការជ្រើសរើសបាដើម្បីធ្វើការបង្កាត់ឱ្យទទួលបានលទ្ធផលល្អក្នុងពេលបង្កាត់។ អ្វីដែលយើងមានការប្រួយបារម្មណ៍គឺការជ្រើសរើសបាខុស ដែលជាហេតុធ្វើឱ្យសត្វមានកូនតិចដូចជា៖

- មេជីវិតរបស់បា(ស្ពែមម៉ាតូសូអ៊ីត)តិច ឬមានសភាពខ្សោយ
- បាជ្រូកបានពាក់មេច្រើនហួសកំលាំង ឬខានពាក់មេយូរថ្ងៃ ខែ
- បណ្តាលមកពីបាជ្រូកនោះធាត់ពេក តឹងពោះ ឆាប់ហត់ បញ្ចេញទឹកកាមតិចហើយមេជីវិតក៏តិច
- បាជ្រូកជាពូជដែលមានកូនតិច បាជ្រូកជាន់ឈាមជាមួយជ្រូកមេដែលត្រូវធ្វើការបង្កាត់
- បណ្តាលមកពីបាជ្រូកមានជំងឺរលូតកូន(Brucellose)រ៉ាំរ៉ៃ
- បណ្តាលមកពីធ្វើការដឹកបាជ្រូកផ្លូវឆ្ងាយនិងយកទៅដល់កន្លែងបង្កាត់ភ្លាមធ្វើការបង្កាត់ភ្លាម។

## ❖ សេចក្តីណែនាំ

ដើម្បីឱ្យការចិញ្ចឹមជ្រូកទទួលបានជោគជ័យអ្នកចិញ្ចឹមត្រូវគោរពតាមការណែនាំរបស់អ្នកបច្ចេកទេស មួយចំនួនដូចតទៅ៖

## ១-ស្វែងយល់ពីទីផ្សារសត្វ

មុននឹងធ្វើការចាប់ផ្តើមចិញ្ចឹម អ្នកចិញ្ចឹមត្រូវចេះស៊ើបសួរព័ត៌មានទីផ្សារសត្វដែលអាចទិញកូនជ្រូកបានល្អដោយតម្លៃសមស្រប និងទីកន្លែងដែលលក់ជ្រូកទៅវិញបានតម្លៃខ្ពស់ជាងគេ។ ត្រូវយល់ដឹងពីពេលវេលាដែលគេត្រូវការសាច់ជ្រូកនាំឱ្យសាច់ជ្រូកលក់បានថ្លៃ ជាពិសេស នៅក្នុងឱកាសបុណ្យប្រពៃណីធំៗ។

## ២-ចំនួនជ្រូកត្រូវដាក់ចិញ្ចឹម

មុននឹងចាប់ការចិញ្ចឹមអ្នកចិញ្ចឹមគួរតែគិតឱ្យបានច្បាស់អំពីចំនួនជ្រូកប៉ុន្មានក្បាលដែលត្រូវទិញមក ដាក់ចិញ្ចឹមដើម្បីឱ្យសមស្របទៅនឹងលទ្ធភាពនៃការរៀបចំទ្រុង ការផ្តល់ចំណី ភាពមមាញឹកជាក់ស្តែងរបស់ក្រុមគ្រួសារ ដើម្បីជៀសវាងការផ្តល់ចំណីមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ និងការថែទាំមិនបានដិតដល់ធ្វើឱ្យមានការប៉ះពាល់ដល់ការលូតលាស់ និងប្រឈមនឹងការឆ្លងជំងឺសត្វ។

## ៣-ទុន ឬថវិកាសម្រាប់ទ្រទ្រង់ក្នុងរយៈពេលចិញ្ចឹម

អ្នកចិញ្ចឹមសត្វត្រូវគិតគូរដល់ការចំណាយផ្សេងៗក្នុងការចិញ្ចឹមសត្វនិងការថែទាំសត្វឱ្យបានល្អដូចជាៈ

- ចំណាយលើការសាងសង់ទ្រុង
- ចំណាយលើការផ្គត់ផ្គង់ចំណី
- ចំណាយលើការថែទាំ និងជីវសុវត្ថិភាព
- ចំណាយលើការធ្វើវ៉ាក់សាំង
- ចំណាយលើការព្យាបាល។

## ៤-ចំណេះដឹង និងបច្ចេកទេសចាំបាច់

ដើម្បីធានាបាននូវសុវត្ថិភាពក្នុងការចិញ្ចឹម អ្នកចិញ្ចឹមគួរតែយល់ដឹងខ្លះៗអំពីបច្ចេកទេសក្នុងការចិញ្ចឹមសត្វមួយចំនួនដូចជាៈ

- ការជ្រើសរើសពូជសត្វមកចិញ្ចឹមឱ្យបានត្រឹមត្រូវ
- ការផ្គត់ផ្គង់ចំណីឱ្យបានត្រឹមត្រូវទាំងបរិមាណ និងគុណភាព
- ការថែទាំសុខភាព និងវិធានការការពារ(ចាក់វ៉ាក់សាំង និងទំលាក់ព្រូន) គឺជាផ្នែកមួយសំខាន់ណាស់ដែលអ្នកចិញ្ចឹមទាំងអស់ត្រូវតែធ្វើ ព្រោះថាបើយើងធ្វើអ្វីប្រកបដោយការផ្សងព្រេងនោះ លទ្ធផលចុងក្រោយ ពិតជាទទួលមិនបានល្អឡើយ។

## ៥-ធ្វើដូចម្តេចដើម្បីឱ្យអ្នកដឹងថាចំណេញឬខាត?(វិភាគផ្នែក សេដ្ឋកិច្ច)

ដើម្បីឱ្យដឹងថាការចិញ្ចឹមសត្វរបស់អ្នកចំណេញ ឬខាតនោះ អ្នកត្រូវតែកត់ត្រារាលចំណាយទាំងអស់ ជាពិសេសថ្លៃដើមទិញជ្រូក ឬកូនជ្រូក ថ្លៃចំណី ថ្លៃថ្នាំការពារ(វ៉ាក់សាំង) ថ្នាំព្យាបាលនិងថ្លៃពលកម្ម។ល។អ្នកត្រូវកត់ត្រារាងរាល់ពេលដែលអ្នកបានចំណាយធ្វើយ៉ាងនេះអ្នកអាចយកទៅទូទាត់ជាមួយប្រាក់ចំណូល(ថ្លៃលក់ជ្រូក) ដើម្បីរកឱ្យឃើញពីការចំណេញ ឬខាតពិតប្រាកដ។

## ៥. ការចិញ្ចឹមជ្រូកយកសាច់

### ៥.១.១ ការជ្រើសរើសកូនជ្រូកមកចិញ្ចឹម

ក្នុងការជ្រើសរើសជ្រូកសាច់មកធ្វើការចិញ្ចឹម យើងចាប់អារម្មណ៍ជាងគេនោះគឺការជ្រើសរើសកូនជ្រូកមកដាក់ចិញ្ចឹម ពីព្រោះយើងតែងតែសង្កេតឃើញថា ការទិញកូនជ្រូកទើបផ្តាច់ដោះមកដាក់ចិញ្ចឹមពុំសូវទទួលបានលទ្ធផលល្អឡើយ គឺដោយសារតែវាមានអត្រាងាប់ខ្ពស់បើយើងធ្វើការប្រៀបធៀបទៅនឹងការទិញកូនជ្រូកធំល្មមមកចិញ្ចឹម(ជ្រូកដែលមានទំងន់ចាប់ពី១០គីឡូក្រាមឡើងទៅ) ទើបជាការល្អ ក្នុងការចិញ្ចឹម។

ដោយឡែកចំពោះការជ្រើសរើសកូនជ្រូកមកចិញ្ចឹមត្រូវពិនិត្យទៅលើពូជវិញ គឺនៅប្រទេសកម្ពុជាយើងកាន់តែមានការលំបាកក្នុងការជ្រើសរើសទៅទៀត ព្រោះពូជជ្រូកទាំងអស់គឺមានពូជចំរុះ ជួនកាលពូជក្នុងស្រុក កាត់ជាមួយពូជបរទេស(ពូជនាំចូល) ជួនកាលពូជក្នុងស្រុកកាត់ជាមួយក្នុងស្រុក។ល។ លក្ខណៈទាំងនេះហើយ ដែលធ្វើឱ្យអ្នកចិញ្ចឹមមិនងាយរកពូជសុទ្ធមក ចិញ្ចឹមបាននោះទេ។





- **លក្ខណៈសម្បត្តិរបស់កូនជ្រូកត្រូវជ្រើសរើសមកចិញ្ចឹម**
  - កូនជ្រូកគ្រប់អាយុផ្តាច់ដោះ(តិចបំផុត៣៥ថ្ងៃ)មានន័យថា កូនជ្រូកដែលអាចចេះស៊ីចំណីបានល្អ
  - បន្ទាប់ពីផ្តាច់ដោះរួច។ ការធំធាត់របស់កូនជ្រូកចាប់ពីផ្តាច់ដោះរហូតដល់អាយុពី៣ទៅ៤ខែ មានការលូតលាស់នៅកំរិតទាបដោយសារតែវាជួបការលំបាកក្នុងការផ្លាស់ប្តូរចំណី និងល័ក្ខខ័ណ្ឌជីវិតថ្មីរបស់វា។ កូនជ្រូកមានសុខភាពល្អ និងចេះស៊ីចំណីបានល្អ
  - កូនជ្រូកមានទំងន់យ៉ាងតិចចាប់ពី ៥គីឡូក្រាមឡើងទៅ
  - កូនជ្រូកណាដែលមានមេបារបស់មានប្រវត្តិល្អ (ពូជល្អ មានសុខភាពល្អ) មានន័យថាជ្រូកដែលស្ថិតនៅជិតខាងយើង ឬនៅកន្លែងចិញ្ចឹមណាមួយដែលយើងអាចទៅទិញផ្ទាល់ តែក៏

មិនត្រូវឆ្ងាយពេកដែរ ព្រោះធ្វើឱ្យមានការលំបាកក្នុងការដឹកជញ្ជូនសត្វចុះខ្សោយកំលាំងនិងស្រ្តេស ផងដែរ ។




## គុណវិបត្តិនៃការទិញជ្រូកពីឈ្មួញដឹកចល័តមកចិញ្ចឹម

ការទិញកូនជ្រូកពីឈ្មួញដឹកលក់ចល័ត គឺយើងមិនបានដឹងថាជ្រូកដែលដឹកលក់ចល័តតាមម៉ូតូនៅតាមផ្លូវនោះគឺយើងពុំបានដឹងពីប្រភពដើម(ពូជ ទីកន្លែង)ពិតប្រាកដនៅទីណានោះទេ។ ហេតុដូចនេះយើងត្រូវធ្វើការប្រុងប្រយ័ត្នក្នុងការជ្រើសរើសកូនជ្រូកមកចិញ្ចឹមព្រោះ៖

- កូនជ្រូកធ្វើដំណើរផ្លូវឆ្ងាយ រលាក់ ផ្លាស់ប្តូរទីកន្លែងញឹកញាប់ក្រោមកំដៅថ្ងៃ ឬត្រជាក់ជួនកាលដាច់ចំណី និងទឹកក៏សឹងតែមាន
- កូនជ្រូកដែលដាក់ក្នុងជុច ឬទ្រុងដឹកតូចចង្អៀតហើយប្រមូលផ្តុំដោយកូនជ្រូកមានដើមកំណើតពីមេឬពីទីកន្លែងផ្សេងៗពីគ្នាដែលជាឱកាសក្នុងការចំលងជំងឺពីជ្រូកមានផ្ទុកមេរោគទៅកូនជ្រូកដែលមានសុខភាពល្អ។ ការដឹកជញ្ជូនសត្វខុសបច្ចេកទេសនេះធ្វើឱ្យសត្វចុះខ្សោយកំលាំង និងងាយទទួលជំងឺឆ្លងផ្សេងៗទៀតកូនជ្រូកដែលដឹកចល័តដោយសារតែពុំបានដឹងពីប្រភពច្បាស់លាស់ជាការពិតណាស់ក្នុងចំណោមកូនជ្រូកទាំងនោះ មានកូនជ្រូកមួយចំនួនបានផ្ទុកមេរោគស្រេចដែលយើងមិនអាចមើលដឹងជាហេតុធ្វើឱ្យមានជំងឺ ឬធ្លាក់ខ្លួនឈឺមិនស៊ីចំណី ញាក់ញ័ររាគ ហើយភាគច្រើនត្រូវបានងាប់បន្ទាប់ពីប៉ុន្មានថ្ងៃក្រោយពេលបានទិញមកចិញ្ចឹម
- កូនជ្រូកខ្លះមានអាយុខ្លីខែ (ផ្តាច់ដោះមិនគ្រប់អាយុ ទំងន់ក្រោម ៩គីឡូក្រាម) វាជាកូនជ្រូកដែលទទួលទឹកដោះពីមេមិនគ្រប់គ្រាន់ វាមានអង់ទីគ័រតិចតួចសម្រាប់ទប់ទល់ទៅនឹងជំងឺឆ្លងផ្សេងៗ និងប្រដាប់រំលាយអាហាររបស់វាមិនទាន់មានការរីកចំរើនក្នុងការរំលាយអាហារ ព្រោះពោះវៀនរបស់វា មិនទាន់មានសមត្ថភាពស្រូបយកសារធាតុចិញ្ចឹមពីអាហារសំរាប់ទ្រទ្រង់សរីរាង្គកាយរបស់វាមិនទាន់បានល្អ ។ ម្យ៉ាងទៀតដោយសារ កូនជ្រូកមិនទាន់ចេះ

ស៊ីចំណីបានល្អវាស៊ីចំណីមិនបានច្រើន ជាហេតុធ្វើឱ្យកូនជ្រូកជួបការលំបាកក្នុងការផ្លាស់ប្តូរចំណី អាហារធ្វើឱ្យកូនជ្រូកបាក់ទឹកដោះចុះខ្សោយកំលាំង ឈឺ និងអាចងាប់បាន។

- ការចងចាំ
  - កូនជ្រូកដែលគេទើបផ្តាច់ដោះ ឬបំបែកពីមេ មានសភាពក្រៀមក្រំ ដោយវាមិនបានបៅដោះនិងរស់នៅឆ្ងាយពីមេរបស់ទៀតផង។ ដូចនេះជាការប្រសើរម្ចាស់ ឬអ្នកចិញ្ចឹមគួរតែទិញកូនជ្រូក ២ក្បាល មកដាក់ចិញ្ចឹមក្នុងពេលដំណាលគ្នាដើម្បីកុំឱ្យវាអផ្សុក និងភ័យខ្លាច ព្រមទាំងផ្តល់ចំណីដល់វាស៊ីឱ្យបាន ញឹកញាប់ ដើម្បីកុំឱ្យវាបាក់ទឹកដោះ
  - កូនជ្រូកទើបទិញភ្លាម ត្រូវដាក់វានៅកន្លែងស្អាតល្អ និងទីកន្លែងដែលមានភាពកក់ក្តៅសម្រាប់វា(ទប់ទល់នឹងភាពត្រជាក់ ព្រោះកូនជ្រូកទាំងនោះឈប់បានទទួលកំដៅពីមេរបស់វាទៀតហើយ) គឺធ្វើយ៉ាងណាកុំដាក់វាឱ្យវានៅផ្ទាល់នឹងដីសើម ឬត្រជាក់ពេកដោយដាក់កំរាលក្រាលពីក្រោម និងកុំឱ្យត្រូវខ្យល់ខ្លាំងពេក ត្រូវយកជាល ឬកញ្ជេរក្រុងឬដាក់វាក្នុងកន្លែងមានជញ្ជាំងព័ទ្ធជុំវិញជាពិសេសនៅពេលយប់ និងនៅពេលអាកាសធាតុត្រជាក់។ល។
  - កូនជ្រូកទើបផ្តាច់ដោះយើងទិញមកចិញ្ចឹមជាការល្អយើងត្រូវផ្តល់ជាតិដែកដល់វា(អាចផ្តល់ឱ្យវានូវថ្នាំចាក់ ឬថ្នាំគ្រាប់)ដើម្បីប្រឆាំងនឹងការខ្វះឈាម(ជំងឺស្លេកស្លាំង) និងជំងឺរាគរូសព្រោះជាតិដែកជួយបង្កើនគ្រាប់ឈាមនៅក្នុងខ្លួនសត្វនាំឱ្យសត្វមានសុខភាពល្អ និងឆាប់ធំធាត់។

## ៥.១.២ អំពីទ្រុង ស្នូកទឹក និងស្នូកចំណី

### អំពីទ្រុង

ជាធម្មតា ទ្រុងគឺជាកន្លែងរស់នៅរបស់សត្វ ហើយទ្រុងសត្វត្រូវបានគេបែងចែកជាច្រើនប្រភេទទៅតាមប្រភេទសត្វ ដូចជាទ្រុងសម្រាប់ដាក់ជ្រូកមេ ទ្រុងជ្រូកបា ទ្រុងជ្រូកមេក្រមុំ ទ្រុងជ្រូកមេត្រៀមដាក់បា(សម្រាប់បង្កាត់) ទ្រុងជ្រូកមេធើម ទ្រុងជ្រូកមេត្រៀមកើតកូន ទ្រុងជ្រូកមេបំបៅកូន ទ្រុងកូនជ្រូកផ្តាច់ដោះ) ទ្រុងជ្រូកសាច់ជាដើម។ល។ ម្យ៉ាងទៀត ទ្រុងត្រូវអនុវត្តទៅតាមទ្រង់ទ្រាយ និងទំហំនៃការចិញ្ចឹម(ចំនួនសត្វនិងការចិញ្ចឹមទៅតាមទំលាប់របស់កសិករនិងទៅតាមតំបន់ ឬតាមរដូវកាលចិញ្ចឹមសត្វដាក់ទ្រុង ដោយចង និងដោយព្រលែងឱ្យដើរ រកចំណីស៊ីដោយសេរី។

### ទំហំទ្រុងទៅតាមប្រភេទជ្រូក

- **ការរៀបចំទ្រុង**: ប្រភេទទ្រុង និងទំហំទ្រុង អាស្រ័យទៅតាមប្រភេទពូជជ្រូក និងទៅ តាមតំបន់ ឬទីតាំងដាក់ស្តែងដែលអាចធ្វើបាន។

| ប្រភេទជ្រូក | ទំហំទ្រុងគិតជាម៉ែត្រការ៉េ (ទ X ប) |
|---|---|
| ជ្រូកក្រមុំ | ១ X ២ |
| មេជ្រូកបំរុង ឬមេជ្រូកដើម | ០.៦៥ X ២.២០ |
| បាជ្រូកមានកន្លែងសម្រាប់បង្គាត់ | ២.៣ X ៤ |
| មេជ្រូកបំបៅកូន | ៣ |
| មេជ្រូកកើតកូន | ២ X ២.៣ |
| កូនជ្រូកផ្តាច់ដោះ | ២.៥ X ៣ (សម្រាប់កូន១២ក្បាល) |
| ជ្រូកសាច់ទំងន់ពី៣០ ទៅ ៦០ គ.ក្រ | ០.៧ X ១ |
| ជ្រូកសាច់ចាប់ពី ៦១ គ.ក្រ ដល់ពេលលក់ | ១ X ១.២ |





## ការសាងសង់ទ្រុង

ការសាងសង់ទ្រុងសម្រាប់ដាក់សត្វចិញ្ចឹម គឺជាកន្លែងរបស់សត្វរស់នៅហើយធ្វើយ៉ាងណាត្រូវឆ្លើយតបទៅនឹងចំណុចមួយចំនួនដូចខាងក្រោមៈ

- ទ្រុងត្រូវសង់នៅលើទីខ្ពស់មិនលិចទឹក នៅឆ្ងាយពីទីប្រជុំជន និងឆ្ងាយពីសត្តឃាតដ្ឋាន
- ទ្រុងត្រូវសង់តាមបណ្តោយថ្ងៃ
- ទ្រុងត្រូវសង់ឲ្យមានពន្លឺនិងខ្យល់ចេញ-ចូលគ្រប់គ្រាន់
- ទ្រុងជ្រូកត្រូវធ្វើកំរាលជញ្ជាំង, ប្រក់ដំបូល
- នៅផ្ទៃបាត ត្រូវចាក់បេតុងត្រើមទាបមួយចំហៀង

- នៅចុងជំរាល ត្រូវធ្វើចង្ហូរសម្រាប់ទឹកហូរចេញ នៅពេលលាងជ្រូក ឬនៅពេលសំអាតទ្រុង
- ចំពោះទ្រុងជ្រូកមេបំបៅកូនត្រូវសង់ឱ្យឆ្ងាយពីជ្រូកសាច់
- ទ្រុងជ្រូកត្រូវរៀបចំឲ្យមានស្នូកទឹកនិងស្នូកចំណី ។




## ប្រភេទគ្រួរជៀសវាង

ទ្រុងមិនត្រូវធ្វើជំរាលខ្ពស់ និងរលោងខ្លាំងពេកទេ ព្រោះបណ្តាលឲ្យជ្រូកថ្លោះ ឬគ្រេច ជើងនៅពេលដើរ។បន្ទាប់មក វាយរបាផ្តេកឲ្យបានញឹកផ្នែកខាងក្រោម(ចន្លោះ១៥សម) ដើម្បីកុំឲ្យកូនជ្រូកចេញរួចឯរបាខាងលើត្រូវទុកចន្លោះ២០សម។ ដំបូលត្រូវប្រក់ឲ្យសល់ហួសជើងរោងយ៉ាងតិច០.៥ម ដើម្បីកុំឲ្យភ្លៀង និងកំដៅជះចូលទៅក្នុងទ្រុងខ្លាំងពេក។ ក្រោយពីធ្វើទ្រុង និងស្នូកទឹក និងចំណីរួច មិនត្រូវយកជ្រូកទៅដាក់ភ្លាមទេ ត្រូវស្រោចទឹកឲ្យបានញឹមញាប់រយៈពេល ១អាទិត្យ ដើម្បីឲ្យអស់ជាតិស៊ីម៉ង់ត៍។ ព្រោះជាតិស៊ីម៉ង់ត៍ធ្វើឲ្យជ្រូកកើតរមាស់។ ត្រូវបាចកំបោរសក្នុងទ្រុង ដើម្បីសំលាប់មេរោគ រួចទុកចោល១អាទិត្យទើបលាងកំបោរនោះចេញ ។

## ការរៀបចំទ្រុង

- ទ្រុងត្រូវសង់នៅលើទីខ្ពស់មិនលិចទឹក នៅឆ្ងាយពីទីប្រជុំជន និងឆ្ងាយពីសត្តឃាតដ្ឋាន
- ទ្រុងត្រូវសង់តាមបណ្តោយថ្ងៃ
- ទ្រុងជ្រូកត្រូវសង់ឲ្យមានពន្លឺនិងខ្យល់ចេញ-ចូលគ្រប់គ្រាន់
- ទ្រុងជ្រូកត្រូវធ្វើកំរាលជញ្ជាំង, ប្រក់ដំបូល
- នៅផ្ទៃបាត ត្រូវចាក់បេតុងគ្រើមទាបមួយចំហៀង នៅចុងជំរាល ត្រូវធ្វើកូនប្រឡាយទឹកសម្រាប់ទឹកហូរចេញនៅពេលលាងជ្រូក ឬនៅពេលសំអាតទ្រុង
- ចំពោះទ្រុងជ្រូកមេបំបៅកូនត្រូវសង់ឱ្យឆ្ងាយពីជ្រូកសាច់
- ទ្រុងជ្រូកត្រូវរៀបចំឲ្យមានស្នូកទឹកនិងស្នូកចំណី

### ការចិញ្ចឹមព្រលែង

ការចិញ្ចឹមជ្រូកលែងឱ្យដើររកចំណីស៊ីខ្លួនឯងដោយសេរី គឺជាវិធីមួយដែលកសិករអនុវត្តជាទូទៅព្រោះពួកគាត់បានយល់ឃើញថា វាមានភាពងាយស្រួលក្នុងការថែទាំ និងផ្តល់ចំណី។ល។ ការចិញ្ចឹមបែបនេះគឺគេលែង ជ្រូកឱ្យដើររកស៊ីចំណីគ្រប់ទីកន្លែង គ្រប់ច្រកល្ហកនៅតាមវាលស្រែ នៅតាមភូមិជាដើម។ ប៉ុន្តែវាមានផលវិបាក និងគុណសម្បត្តិមួយចំនួនដូចខាងក្រោមៈ

#### គុណសម្បត្តិ

- មិនចាំបាច់ចំណាយពេល និងថវិកាក្នុងការសាងសង់ទ្រុង
- ជ្រូកអាចដើររកចំណីស៊ីដោយខ្លួនបានមួយផ្នែកនៅតាមវាល
- ចំណាយពេលតិចក្នុងការថែទាំជ្រូកប្រចាំថ្ងៃ

#### គុណវិបត្តិ

- ការដើររកចំណីស៊ីដោយខ្លួនឯងមិនអាចបំពេញតាមតម្រូវការរបស់វាបានទេសម្រាប់ការធំធាត់ការបន្តពូជ
- ជ្រូកចិញ្ចឹមលែងផ្តល់ផលអាក្រក់ច្រើនដល់អ្នកជិតខាង(បំផ្លិចបំផ្លាញដំណាំបង្កជំលោះ) អ្នកជិតខាង
- មានការលំបាកក្នុងការថែទាំប្រចាំថ្ងៃ ដូចជាការតាមដានសុខភាពសត្វប្រចាំថ្ងៃរបស់សត្វការ
- តាមដានជំងឺ ការបង្កើតកូន(មានមេជ្រូកមួយចំនួនបានកើតកូនដោយខ្លួនឯងពុំមានការអន្តរាគមន៍ ពីម្ចាស់ នៅឯក្នុងព្រៃឆ្ងាយពីផ្ទះ)
- ជ្រូកងាយទទួលរងគ្រោះថ្នាក់ដោយជំងឺឆ្លងផ្សេងៗ និងដោយការវាយប្រហារពីអ្នកជិតខាង
- អ្នកមិនពេញចិត្តដោយការបំពុលដោយធ្លាក់រណ្តៅគ្រោះថ្នាក់ចរាចរ ឬមានអំពើចារកម្ម។ល។
- ករណីជ្រូកមានជំងឺ ពេលវាដើររកស៊ីពាសវាលពាសកាលនោះ គឺវានឹងដើរតួនាទីជាអ្នកចំលងជំងឺដល់សត្វផ្សេងៗទៀតដែលនៅជិតខាង។

- **ការចិញ្ចឹមសត្វដាក់ទ្រុង ឬចង**

ការចិញ្ចឹមសត្វដាក់ទ្រុង និងចងត្រូវបានគេអនុវត្តនៅរដូវដាំដុះ ឬនៅតាមតំបន់ដែលមានគេដាំដំណាំជាប្រចាំ។ ការចិញ្ចឹមសត្វដាក់ទ្រុង ឬចង មានគុណសម្បត្តិ និងគុណវិបត្តិដូចខាងក្រោមៈ

#### គុណសម្បត្តិ

- យើងអាចធ្វើការចិញ្ចឹមសត្វបានទោះបីជាមានផ្ទៃដីតូចចង្អៀតក៏ដោយ
- ងាយស្រួលក្នុងការថែទាំសុខភាពសត្វប្រចាំថ្ងៃ(ពេលឈឺស្កាត់ពេលកើតកូន...។ល។) កំណើន ទំងន់ ការព្យាបាល ការធ្វើវ៉ាក់សាំង

- កាត់បន្ថយនូវគ្រោះថ្នាក់ផ្សេងៗ ការឆ្លងជំងឺ គ្រោះថ្នាក់ដោយយថាហេតុ និងអំពើចារកម្ម
- រារាំងសត្វបំផ្លាញដំណាំរបស់អ្នកជិតខាងដោយសារការលែងឱ្យសត្វដើររកចំណីស៊ីដោយសេរី
- ការពារសត្វពីការទំនាក់ទំនងជាមួយសត្វខាងក្រៅ(ឆ្កែ ឆ្មា និងសត្វព្រៃផ្សេងៗទៀត)
- ងាយស្រួលប្រមូលលាមក និងទឹកនោមសត្វសម្រាប់រក្សាទុកធ្វើជាជីដាក់ដំណាំ។

**គុណវិបត្តិ**

- ចំណាយថវិកាច្រើនសម្រាប់សាងសង់ទ្រុង និងទិញចំណីឱ្យសត្វស៊ី
- ត្រូវមានទីកន្លែងសមស្របសម្រាប់សាងសង់ទ្រុង និងដាក់សត្វចិញ្ចឹម
- ទាមទារការថែទាំ ធ្វើអនាម័យ និងធញ្ញវេជ្ជជីវសុវត្ថិភាពជាប្រចាំ។

- **ការសាងសង់ជំរក**

ជំរកជាកន្លែងរស់នៅរបស់សត្វ ហើយម្ចាស់សត្វ ឬអ្នកចិញ្ចឹមត្រូវសាងសង់ជំរក ធ្វើយ៉ាងណា ដើម្បីឱ្យឆ្លើយតបទៅនឹងចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ត្រូវការពារសត្វឱ្យផុតពីកំដៅព្រះអាទិត្យ ខ្យល់បក់ខ្លាំង និងទឹកភ្លៀងសាច
- ត្រូវមានខ្យល់អាកាសចេញ-ចូលបានល្អ និងមានលំហគ្រប់គ្រាន់សម្រាប់សត្វរស់នៅ
- ត្រូវបង្កលក្ខណៈងាយស្រួលដល់ការផ្តល់ទឹក ចំណី និងការធ្វើអនាម័យ
- ក្នុងទ្រុងសត្វត្រូវធ្វើយ៉ាងណាកុំឱ្យមានការប្រែប្រួលសីតុណ្ហភាពខ្លាំងពេកទេ មានន័យថា បើក្តៅ កុំឱ្យក្តៅពេក បើត្រជាក់កុំឱ្យត្រជាក់ពេក គឺត្រូវធ្វើយ៉ាងណាឱ្យមានលំនឹងនៃសីតុណ្ហភាពនៅក្នុងទ្រុងសត្វ។

**ឧទាហរណ៍:** ម្ចាស់ឬអ្នកចិញ្ចឹមសត្វត្រូវសាងសង់ទ្រុងនៅក្រោមដើមឈើដែលមានម្លប់ ព្រោះដើមឈើអាចស្រូបយកកំដៅពីព្រះអាទិត្យបានល្អ ហើយវាអាចជួយសម្រួលសីតុណ្ហភាពឱ្យមានលំនឹងនៅក្នុងទ្រុង។ លក្ខណៈទាំងនេះហើយដែលធ្វើឱ្យសត្វមានសុខភាពល្អ កាត់បន្ថយអត្រាឈឺ ឬងាប់មានការថយចុះ និងសត្វមានការលូតលាស់ធំធាត់លឿន។





- **កំរាលបាតទ្រុង**

ដីបាតទ្រុងត្រូវរឹងល្អ រាបស្មើ ដើម្បីងាយស្រួលដល់ការការលាងសំអាត និងការធ្វើអនាម័យ។ ហាមសាងសង់ទ្រុងសត្វនៅលើដីជ្រាបទឹកដែលបង្កឱ្យមានភាពក្រខ្វក់ដែលជាប្រពភចំលងជំងឺផ្សេងៗ ជាពិសេសជំងឺបរាស៊ីត។ ក្រៅពីនេះគេអាចប្រើប្រាស់ក្តាបន្ទះ ជ័រ ឬចាក់បេតុងដើម្បធ្វើកំរាលនៃបាតទ្រុងសត្វ។ ជាការប្រសើរកំរាលបាតទ្រុងសត្វគួរធ្វើឱ្យមានជំរាលបន្តិច ដើម្បីងាយស្រួលក្នុងការបង្ហូរទឹក និងកាក់សំណល់របស់សត្វចេញពីក្នុងទ្រុង ជាពិសេស គឺក្នុងពេលយើងធ្វើអានាម័យ។ ម្យ៉ាងទៀត យើងអាចជីរណ្តៅ ឬ ធ្វើឡជីវឧស្ម័នមួយនៅក្បែរទ្រុងសត្វសំរាប់ស្តុកលាមកសត្វ ទឹកនោមសត្វដែលយើងកើប ឬបង្ហូរចូលនៅពេល ធ្វើអនាម័យទ្រុង។ ចំពោះកាកសំណល់ដែលហូរចេញពីឡជីវឧស្ម័នគឺជាជីធម្មជាតិដ៏ល្អសម្រាប់ដាក់ ឬស្រោចដំណាំផ្សេងៗព្រមទាំងបានជួយបំបាត់ក្លិនផងដែរ។ គេអាចធ្វើកំរាលបាតទ្រុងសត្វឱ្យខ្ពស់ជាងដីធម្មតា បន្តិចដើម្បីការពារកុំឱ្យទឹកភ្លៀងហូរ ឬហូរជ្រោះនៅរដូវវស្សា។




- **ដំបូល និងជញ្ជាំង**

ដំបូល និងជញ្ជាំង គឺមានតួនាទីយ៉ាងសំខាន់ក្នុងការការពារសត្វឱ្យផុតពីកំដៅព្រះអាទិត្យ និងទឹកភ្លៀង ដូច្នេះ ការសាងសង់ យើងត្រូវតែប្រក់ដំបូល និងបាំងជញ្ជាំងដល់ទ្រុងដើម្បីផ្តល់នូវម្លប់ និងការពារទឹកភ្លៀងដល់សត្វ។ចំពោះសម្ភារៈសម្រាប់ធ្វើដំបូលទ្រុងត្រូវធ្វើឡើងពីវត្ថុដែលមិនទទួលការចំលងកំដៅព្រោះវាអាចទប់ទល់កំដៅព្រះអាទិត្យបានល្អ មិនឱ្យកំដៅទៅប៉ះពាល់ផ្ទាល់លើខ្លួនសត្វដូចជាស្លឹកត្នោតស្បូវ ប៉ុន្តែជញ្ជាំងទ្រុងត្រូវតែធ្វើយ៉ាងណាឱ្យភាពរឹងមាំ និងជិតល្អ ដើម្បីបង្ការកុំឱ្យជ្រូកបំផ្លាញ និង សត្វផ្សេងទៀតអាចចេញ ចូលក្នុងទ្រុងបាន។ ម្យ៉ាងទៀត ការធ្វើដំបូលទ្រុងត្រូវធ្វើឱ្យបានខ្ពស់ កុំធ្វើទាបពេកហើយដំបូលទ្រុងត្រូវមាន ២ផ្ទាំង។ មិនត្រូវបង្ខាំងសត្វជ្រូកនៅក្នុងទ្រុងងងឹត គ្មានពន្លឺគ្រប់គ្រាន់ តូចចង្អៀត គ្មានខ្យល់ ចេញចូលគ្រប់គ្រាន់ មានក្លិនស្អុយ និងកំរាលទ្រុងមានសភាពសើមជោគជាំជាប្រចាំធ្វើឱ្យមានការប៉ះពាល់ដល់សុខភាពសត្វចុះខ្សោយ ងាយទទួលជំងឺឆ្លងផ្សេងៗ និងធ្លាក់ខ្លួនឈឺ។





- **ទំហំទ្រុង**

  យើងដឹងហើយថាជ្រូក ត្រូវការទំហំកន្លែងគ្រប់គ្រាន់សម្រាប់រស់នៅគឺ:

  - ជ្រូកសាច់ ១ក្បាលត្រូវការផ្ទៃដី ១.៥ម៉ែត្រការ៉េ
  - បើយើងមានទ្រុងទំហំ ២០ម៉ែត្រការ៉េយើងអាចដាក់កូនជ្រូកបានចំនួន ២០ក្បាល ឬជ្រូកសាច់ចំនួន១០ក្បាល។





- **ការធ្វើស្នូកទឹក និងស្នូកចំណី**

ជាការប្រសើរណាស់ចំពោះការចិញ្ចឹមសត្វគឺយើងត្រូវមានស្នូកទឹកនិងស្នូកចំណីនៅដាច់ដោយឡែកពីគ្នា។ ម្ចាស់សត្វ ឬអ្នកចិញ្ចឹម ចាំបាច់ត្រូវធ្វើស្នូកចំណីជាប់នឹងកន្លែងដោយ លៃយ៉ាងណាកុំឱ្យសត្វអាចផ្ដួលបានដែលជាហេតុបណ្ដាលឱ្យមានការខ្ជះខ្ជាយចំណី(ធ្វើឱ្យប្រឡាក់ប្រឡូកក្នុងទ្រុង កខ្វក់ចំណី។ ចំពោះស្នូកទឹកក៏ធ្វើដូច្នេះដែរ។ ប៉ុន្តែបច្ចុប្បន្នស្នូកចំណីត្រូវបានគេធ្វើពីបេតុងព្រោះប្រើបានយូរ មានទំហំ

ប្រវែងបណ្ដោយ០.៧៥ម៉ែត្រ ទទឹង០.៣៥ម៉ែត្រ និងជំរៅ ០.៣០ម៉ែត្រ សម្រាប់ជ្រូក១ក្បាល និងស្នូក ទឹកមិនត្រូវបានគេធ្វើជាប់នៅនឹងកន្លែងផ្ទាល់នោះទេភាគច្រើនគេនិយម ប្រើរ៉ូប៊ីណេ(ក្បាលបើត) ដាក់នឹងជញ្ជាំងទ្រុង ដោយភ្ជាប់ជាមួយទុយោរទឹកសម្រាប់ឱ្យជ្រូកបឺតទឹកផឹកផ្ទាល់តែម្ដង។ វិធីនេះល្អបំផុតសម្រាប់ការចិញ្ចឹម ជ្រូកព្រោះវាធ្វើឱ្យទឹកស្អាត មិនជូរផ្អូម ឬគេអាចប្រើធុងទឹកដាក់ បង្ហូរឲ្យជ្រូកផឹកដោយប្រើរ៉ូប៊ីណេធ្វើឲ្យយើងមិនពិបាកលាងសំអាតរាល់ថ្ងៃ។





## ៥.១.៣ ចំណី និងការផ្ដល់ចំណី

ចំណីគឺជាកត្តាសំខាន់ជាងគេក្នុងការចិញ្ចឹមសត្វ ព្រោះចំណីសម្រាប់ធ្វើឱ្យសត្វធំធាត់ មានសុខភាពល្អ និងសម្រាប់បង្កើនការបន្តពូជ។ ដូចនេះដើម្បីធានាឱ្យបាននូវការលូតលាស់ល្អ ធ្វើឱ្យមានសុខភាពល្អ អ្នកចិញ្ចឹម ឬម្ចាស់សត្វត្រូវផ្ដល់ចំណីឱ្យសត្វស៊ីឱ្យបានគ្រប់គ្រាន់ និងមានគុណភាព។ ប៉ុន្តែតាមការសង្កេត ក្នុងការចិញ្ចឹមសត្វជ្រូករបស់ប្រជាពលរដ្ឋនៅប្រទេសកម្ពុជាយើងការផ្ដល់ចំណីឱ្យជ្រូកស៊ីភាគច្រើនគឺកន្ទក់ និងបាយបន្តិចបន្តួចដោយហាន់ដើមចេកបុកដាក់លាយជាមួយ តែក៏មានភាពខុសគ្នាបន្តិចបន្តួចទៅតាមតំបន់ដោយតំបន់មួយចំនួនបានផ្ដល់ឱ្យជ្រូកស៊ីនៅបន្លែស្រស់ កាកសំណល់ផ្ទះបាយ និងចំណីផ្សំស្រេចពី ក្រុមហ៊ុន។ យើងដឹងហើយថាចំណីគឺជាអ្នកផ្ដល់នូវថាមពល ប្រូតេអ៊ីន សារធាតុរ៉ែ និងវីតាមីនសម្រាប់ទ្រទ្រង់ជីវិតរបស់សត្វក៏ដូចជាជីវិតរបស់មនុស្សយើងប្រចាំថ្ងៃផងដែរ។ វត្ថុធាតុដើមសម្រាប់យកមកផលិតជាចំណីមានសារធាតុចិញ្ចឹមផ្សេងៗគ្នាដូចជា:

- **ចំណីផ្ដល់ថាមពល**

វត្ថុធាតុដើមសម្រាប់ផ្សំជាចំណីសត្វដែលបានផ្ដល់នូវថាមពលមានដូចជា ពពួកពោត កន្ទក់ ចុងអង្ករ ស្រូវ ដំឡូងមី ដំឡូងជ្វា ស្ករ ខ្លាញ់ ប្រេង។ល។ ថាមពលមានតួនាទីសំខាន់ណាស់ក្នុងសារពាង្គកាយសត្វ ដល់ការបង្កើតកំដៅ និងរក្សាកំដៅក្នុងខ្លួនសត្វឱ្យមានតុល្យភាព ផ្ដល់កំលាំង ឱ្យសត្វធ្វើសកម្មភាព (ដើរ ដេក ឈរ និងលោតបានដោយសេរី) ធ្វើឱ្យសត្វមានសុខភាពល្អ និងអាចការពារ

ការរាតត្បាតនៃមេរោគជំងឺឆ្លងសត្វមួយចំនួនទៀតផង។ ម្យ៉ាងទៀតពពួកចំណីជាតិម្សៅ និងស្ករ វាមានអំពើសំខាន់ៗកើតឡើង ហើយត្រូវបានថ្លើមបំលែងឱ្យទៅជាខ្លាញ់សម្រាប់ស្តុកក្នុងខ្លួនសត្វ។ដូច្នេះ ប្រសិនបើអ្នកចិញ្ចឹម ឬម្ចាស់សត្វ ផ្តល់នៅចំណីដែលសំបូរទៅដោយថាមពលច្រើន(ជាតិម្សៅ និងស្ករ) នាំឱ្យសត្វជ្រុកធាត់ និងសំបូរ ទៅ ដោយជាតិខ្លាញ់ច្រើន។ កាលណាសត្វខ្វះថាមពល នាំឱ្យសត្វរងាញាក់ញ័រ (ចាញ់អាកាសធាតុត្រជាក់) ចុះខ្សោយកំលាំងថយភាពធន់ប្រឆាំងទៅនឹង មេរោគនាំឱ្យសត្វងាយទទួល ជំងឺឆ្លងផ្សេងៗ។ ផ្ទុយទៅវិញ ប្រសិនបើចំណីខ្វះនូវសារធាតុអាមីដុង(ជាតិម្សៅ)ថ្លើមក៏អាចបំលែងខ្លាញ់ឱ្យ ទៅជាស្ករ ដើម្បីឱ្យសារពាង្គកាយសត្វអាចប្រើប្រាស់បាន។

- **ចំណីផ្តល់ជាតិប្រូតេអ៊ីន**(**ជាតិសាច់**)

វត្ថុធាតុដើមសម្រាប់ផ្សំជាចំណីសត្វដែលបានផ្តល់នូវជាតិប្រូតេអ៊ីនមានដូចជា ពពួកសណ្តែកសៀង សាច់ ស៊ុត ត្រី ម្សៅត្រី។ល។ សារធាតុប្រូតេអ៊ីនមានតួនាទីសំខាន់សម្រាប់ទ្រទ្រង់ជីវិត ដើម្បីបង្កើតសាច់ ទឹកដោះ បង្កើតកូនបានច្រើន (ផលិតមេជីវិតសត្វមេបានច្រើន) កូនល្អ បង្កើតកោសិកា បង្កើតឈាម និង ចូលរួមគ្រប់តួនាទីនិងសកម្មភាពរបស់សរីរាង្គ ជាពិសេសចូលរួមក្នុងការបង្កើតអង់ទីគ័រប្រឆាំងទៅនឹង មេរោគនៃជំងឺឆ្លងសត្វ។ ចំពោះសត្វ រាង្គកាយរបស់វាពុំមានលទ្ធភាពផ្ទុកប្រូតេអ៊ីនពីចំណីទេ អ្នកចិញ្ចឹម ឬ ម្ចាស់សត្វ គម្បីត្រូវផ្តល់ជាតិប្រូតេអ៊ីនឱ្យវាបានគ្រប់គ្រាន់រៀងរាល់ថ្ងៃ ដើម្បីបង្កើតកោសិការបស់សារពាង្គ កាយសត្វតាមរយៈនៃការផ្តល់ចំណីដែលសំបូរទៅដោយប្រូតេអ៊ីន។ ជាទូទៅ ប្រសិនបើនៅក្នុងចំណីខ្វះជាតិ ប្រូតេអ៊ីននាំឱ្យសរីរាង្គសត្វទ្រុឌទ្រោមចុះខ្សោយ ស្លេកស្រពន់ ក្រិនរោមបះមិនចង់ស៊ីចំណី ការរំលាយ អាហារខ្សោយការលូតលាស់យឺតការបន្តពូជយឺត (បន្លាយពេលយូរ) ការផលិតទឹកមេជីវិត(ស្ពែម)ខ្សោយ ការបង្កកំណើតកូនមិនល្អ (មានចំនួនតិច) និងងាយទទួលជំងឺឆ្លង ផ្សេងៗទៀត។

- **វត្ថុធាតុដើមសម្រាប់ផ្សំចំណីផ្តល់សារធាតុវីតាមីន**(**ជីវជាតិ**)

វីតាមីន ជាសារធាតុដែលសរីរាង្គត្រូវការបន្តិចបន្តួច និងមានតួនាទីសម្រាប់ការរស់រានមានជីវិត ការធំ ធាត់ ការលូតលាស់ ការបន្តពូជ ការទ្រទ្រង់ និងការពារប្រព័ន្ធប្រសាទ និងជួយដល់ចក្ខុវិញ្ញាណជាដើម។ ការ ផ្សំចំណីប្រសិនបើកង្វះសារធាតុវីតាមីន ធ្វើឱ្យសត្វចុះខ្សោយ ការលូតលាស់យឺត ការបន្តពូជមានល្អ ឬសត្វ មិនបង្កកំណើត(អា)ប្រព័ន្ធប្រសាទខ្សោយ និងចក្ខុវិញ្ញាណខ្សោយ។ វីតាមីនត្រូវបានគេបែងចែកជាពីរប្រភេទគឺៈ

- **វីតាមីនដែលរលាយក្នុងប្រេងៈ ពពួកវីតាមីន** A, D, E, K,

**វីតាមីនអា** (A) មានតួនាទីសំខាន់ណាស់ក្នុងការចូលរួមជំរុញការបន្តពូជ ការលូតលាស់ា ការធំ ធាត់ ធ្វើឱ្យភ្នែកមានពន្លឺភ្លឺច្បាស់ ធ្វើការផ្លាស់ប្តូរនូវកោសិកាផ្សេងៗ ជាពិសេសកូនក្នុងពោះ និងចូលរួមក្នុង ការផ្លាស់ប្តូរសារធាតុផ្សេងៗនៅក្នុងសរីរាង្គសត្វ។ កង្វះនូវសារធាតុវីតាមីននេះ ធ្វើឱ្យសត្វមានការលូតលាស់ ធំធាត់យឺត ភ្នែក របស់វាមើលមិនសូវឃើញ (ខ្វាក់មាន់) ប្រព័ន្ធសរសៃប្រសាទខ្សោយ ហើមភ្នែក សត្វអត់កូន

និងស្បែករបស់វាត្រូវខូចខាត អន់ចំណី លទ្ធភាពការពារប្រឆាំងទប់ទល់ទៅនឹងមេរោគជំងឺឆ្លងរបស់ភ្នាស ស្តើងខ្សោយ ធ្វើឱ្យសត្វងាយទទួលរងនូវជំងឺឆ្លងផ្សេងៗ។ វីតាមីនអា(A) មានប្រភពពីសត្វ និងរុក្ខជាតិដូចជាៈ

- វីតាមីនអា(A) មានប្រភពពីសត្វមានដូចជាៈ ខ្លាញ់ថ្លើម ទឹកដោះគោ ស៊ុត និងទឹកដោះដំបូងរបស់មេ។
- វីតាមីនអា(A) មានប្រភពពីរុក្ខជាតិមានដូចជាៈ រុក្ខាជាតិបៃតង ការ៉ុត ល្ពៅ ប៉េងប៉ោះ ត្រកួន ពោតក្រហម។ល។

**វីតាមីនដេ**( D)មានតួនាទីសំខាន់ក្នុងការធ្វើសំយោគកាល់ស្យូម(Ca) និងផូស្វ័រ(P)និងជាអ្នកដឹកជញ្ជូនកាល់ស្យូម(Ca) និងផូស្វ័រ P)ទៅឆ្អឹង ហើយស្រូបយកកាល់ស្យូម(Ca) និងផូស្វ័រ(P)ពីឆ្អឹងមកវិញនៅពេលសារពាង្គកាយត្រូវការប្រើប្រាស់។ ការផលិតចំណី ប្រសិនបើខ្វះនូវីតាមីនដេ(D) ធ្វើឱ្យសត្វមានការលូតលាស់ធំធាត់យឺត ធ្វើឱ្យសត្វមានសភាពគ្រិន រលាកពោះវៀន និងហើមសួត។ ប្រសិនបើកង្វះវីតាមីននេះអូសបន្លាយរយៈពេលយូរធ្វើឱ្យឆ្អឹង និងសន្លាក់ឆ្អឹងមានការរីកធំ ឆ្អឹងមានសភាពទន់ ស្រួយ និងងាយបាក់។ វីតាមីនដេ(D) មានប្រភពពីថ្លើម ទឹកដោះ ខ្លាញ់ ចំណីឡើងមេ ពន្លឺព្រះអាទិត្យ និងនៅក្នុងប្រូវីតាមីន A (ការ៉ូតែន)។

**វីតាមីនអឺ** (E) មានតួនាទីសំខាន់ក្នុងការបង្កកំណើត ការការពារវីតាមីនអា(A) និងជួយការពារសាច់ដុំ និងប្រព័ន្ធប្រសាទ។ ការផលិតចំណីប្រសិនបើខ្វះវីតាមីនអឺ( E) ធ្វើឱ្យសត្វអត់កូន(អា) មេជីវិត(ទឹកស្លេម) មិនអាចបង្កកំណើតបាន កូននៅក្នុងពោះការលូតលាស់មិនបានល្អ ឬការលូតលាស់របស់យឺត ឬអាចងាប់កូនក្នុងពោះ។ ចំពោះមេអាចធ្វើឱ្យខ្វះទឹកដោះសម្រាប់ឱ្យកូនបៅ និងការបន្តពូជយឺត (ខ្សោយ)។ វីតាមីនអឺ (E) មានប្រភពមកពី បន្លែបៃតងពន្លកធញ្ញជាតិ ខ្លាញ់ កន្ទក់ ស៊ុត និងទឹកដោះមានតិចតួច។

**វីតាមីនបេ** (B) មានតួនាទីការពារស្បែក ធ្វើឱ្យស្បែករលោង បណ្តុះរោមបានល្អ ការពារ និងជំនួយសរសៃប្រសាទ ជួយបង្កើតឈាម ជួយបង្កើនកំដៅក្នុងខ្លួនរបស់សត្វ ជួយឱ្យសត្វឃ្លានចំណី។ ការផលិតចំណី ប្រសិនបើខ្វះនៅវីតាមីនបេ(B)ធ្វើឱ្យសត្វស៊ីចំណីតិចស្រកទំងន់ សកម្មភាព ប្រព័ន្ធប្រសាទខ្សោយ ឈរត្រេតទ្រោត ហើមក្បាល រលាកភ្នែ របកស្បែក ស្បែករបស់សត្វមានភាពស្ងួត ហើយរឹងជ្រុះរោម ដើរវិវង់ ញាក់ញ័រ ក្អួត និងការលូតលាស់ធំធាត់យឺត។ ពពួកវីតាមីនបេ ( B) មានប្រភពមកពី កន្ទក់ កាកស្រា កាកស្រាបៀរ ចំណីឡើងមេ ម្សៅទឹកដោះ ម្សៅត្រី ម្សៅសាច់ ម្សៅឈាម បនម្លៃស្រស់ ឃ្លោក គ្រាប់ធញ្ញជាតិ និងគ្រាប់ស្មៅជាដើម។

**វីតាមីនសេ** (C)សត្វជ្រូកត្រូវការវីតាមីនសេ(C)ពេលវាមានជំងឺ ឬឈឺ(ក្នុងការព្យាបាលជំងឺ) និងនៅពេលវាស្ត្រេស។ប៉ុន្តែនៅពេលសត្វមានសុខភាពល្អ(ធម្មតា)សត្វអាចផលិតនៅវីតាមីន(C)បានដោយខ្លួនឯង។

- **ចំណីផ្តល់សារធាតុរ៉ែ**

សារធាតុរ៉ែនៅក្នុងចំណីសត្វមានសារៈសំខាន់ណាស់ក្នុងការទ្រទ្រង់ជីវិតរបស់សត្វហើយក៏ជាផ្នែក

មួយយ៉ាងសំខាន់សម្រាប់បង្កើត និងការលូតលាស់គ្រោងឆ្អឹងរបស់សត្វ ហើយមានតួនាទីតួនាទី និងមុខងារផ្សេងៗទៀតនៅក្នុងឈាម សាច់ដុំ ទឹកដោះ។ល។ ចំណីសម្រាប់ផ្តល់ឱ្យសត្វគឺ ត្រូវការបរិមាណកាលស្យូម និងផូស្វ័រច្រើន។ ចំណែកឯសូដ្យូម អំបិល ជាតិដែក ម៉ាញ៉េស្យូម ម៉ង់កាណែស ស្ពាន់ធ័រ សង្កសី អ៊ីយ៉ូត គឺត្រូវការតែបន្តិចបន្តួចប៉ុណ្ណោះ។ ម្យ៉ាងទៀត កាល់ស្យូម និងផូស្វ័រ ត្រូវការចាំបាច់បំផុតចំពោះមេជើម និងសត្វមេបំបៅកូនច្រើនជាងសត្វផ្សេងៗទៀត ព្រោះវាត្រូវការសម្រាប់ការលូតលាស់ និងការធំធាត់របស់កូន។ សារធាតុទាំងពីរនេះ គឺមានទំនាក់ទំនងគ្នាក្នុងធ្វើឱ្យសត្វសភាពរឹងមាំ និងមានសុខភាពល្អ។ សារធាតុរ៉ែមានផ្ទុកបរិមាណយ៉ាងច្រើននៅក្នុងសារពាង្គកាយសត្វ ជាពិសេសគឺឆ្អឹងកាលស្យូម៩៩% និងផូស្វ័រ៨៨%។ ក្នុងនោះកាលស្យូម ១%ទៀតមានលក្ខណៈជាអំបិលដែលសំរួលដល់ការយឺតរបស់សាច់ដុំ ឈាមកក និងបណ្តូរសារធាតុក្នុងសរីរាង្គសត្វ។ កង្វះសារធាតុ កាលស្យូម និងផូស្វ័រធ្វើឱ្យសត្វក្រិន ឆ្អឹងមិនលូតលាស់ ឆ្អឹងទន់ ស្គីក ឆ្អឹងស្រួយងាយបាក់ ខ្វះទឹកដោះ រលាកសន្លាក់។ ការលស្យម និងផូស្វ័រ មានប្រភពពីម្សៅឆ្អឹង ខ្យង ខ្ចៅ លៀស គ្រំ សំបកងាវ។ល។




- **អំបិល**

អំបិល គឺជាសារធាតុម្យ៉ាង ដែលផ្តល់នូវរស់ជាតិ នៅពេលសត្វស៊ីចំណីអំបិលបានធ្វើឱ្យសត្វដឹងពីរស់ជាតិឆ្ងាញរបស់ចំណីនោះ ហើយវាជួយសម្រួលដល់ការរំលាយអាហារ និងធ្វើឱ្យសត្វផឹកទឹកបានច្រើនដើម្បីជួយសម្រួលដល់ប្រព័ន្ធឈាមរត់ក្នុងសរសៃឈាមរបស់សត្វ។

- **ជាតិដែក**

ជាតិដែកមានសារៈសំខាន់ និងត្រូវការចាំបាច់សម្រាប់សត្វដែលមានអាយុក្រោម ៣អាទិត្យ។ ជាតិ ដែកបានចូលរួមក្នុងការបង្កើតគ្រាប់ឈាមក្រហមក្នុងខ្លួនសត្វនិងធ្វើឱ្យស្បែកសត្វឡើងក្រហមរលោង និងការលូតលាស់ធំធាត់លឿន។ ការផ្សំចំណីសម្រាប់សត្វ ខ្វះជាតិដែកធ្វើឱ្យសត្វរាគរូស សត្វមានសភាពស្លេក

ស្លាំង ខ្វះឈាម និងការលូតលាស់ ធំធាត់យឺត។ ជាតិដែកមានប្រភពពីដីក្រហម(ដីឥដ្ឋ) ត្រកួន និងបន្លែស្រស់ផ្សេងៗទៀត។

**វត្ថុធាតុដើមសម្រាប់ផ្សំចំណីដែលត្រូវបានគេប្រើប្រាស់ និងអាចប្រើប្រាស់ រួមមាន:**

| ល.រ | ប្រភេទវត្ថុធាតុដើមសម្រាប់ផ្សំចំណីចិញ្ចឹមជ្រូកខ្លាតធំ | |
|---|---|---|
| | សមាសធាតុផ្សំ | គ.ក្រ |
| ១ | ពោត | ១៥៣.៥ |
| ២ | កន្ទក់ | ៧៥ |
| ៣ | ចុងអង្ករ | ១៥០ |
| ៤ | សណ្តែកសៀង | ៤០ |
| ៥ | ត្រី ឬម្សៅត្រី | ១០ |
| ៦ | អំបិល | ២.៥ |
| ៧ | សំបកខ្យង | ៥.០០ |
| ៨ | Lysine | ១.៤០ |
| ៩ | Methionine | ០.៤០ |
| ១០ | Threonine | ០.៧០ |
| ១១ | Antimold | ១.៦០ |
| ១២ | Mono-Ca | ៩.០០ |
| ១៣ | Premix | ១.២៥ |
| សរុប | | ៤៥០.៣៥គ.ក្រ |

**រូបមន្តផ្សំចំណីសម្រាប់កូនជ្រូក**

| ល.រ | ប្រភេទវត្ថុធាតុដើមផ្សំចំណី | កូនជ្រូកចេះស៊ីបាយ-២០គ.ក្រ |
|---|---|---|
| ១ | ចុងអង្ករ | ៥៥% |
| ២ | ម្សៅត្រី | ៥% |
| ៣ | អេចភី៣០០ | ៧% |
| ៤ | កាកសណ្តែកសៀង ឬកន្ទក់សៀង | ១៥% |
| ៥ | ម្សៅទឹកដោះគោ | ១០% |
| ៦ | ប្រេងឆា | ៣% |
| ៧ | បាសម៉ិចកូនជ្រូក | ៥% |
| សរុប | | ១០០% |

**រូបមន្តផ្សំចំណីសម្រាប់ជ្រូកចិញ្ចឹមយកសាច់**

| ល.រ | ប្រភេទវត្ថុធាតុដើមផ្សំចំណី | ជ្រូក ២០-៦០គ.ក្រ | ជ្រូក ៦០គ.ក្រ-លក់ |
|---|---|---|---|
| ១ | ចុងអង្ករ | ៣៧% | ៤២% |
| ២ | កន្ទក់ | ២៥% | ៣០% |
| ៣ | ម្សៅត្រី | ៤% | ២% |
| ៤ | អេចភី៣០០ | ៧% | ២% |
| ៥ | កាកសណ្តែកសៀង ឬកន្ទក់សៀង | ២០% | ១៨% |
| ៦ | កន្ទក់សណ្តែកបាយ | ៥% | ៥% |
| ៧ | ខ្លាញ់ត្រី ឬប្រេងឆា | ២% | ២% |
| ៨ | សំបកងាវ | ១% | ១% |
| ៩ | ប្រេម៉ិច | ០.៥០% | ០.២៥% |
| ១០ | អង់ស៊ីម | ០.២០% | ០.១០% |
| ១១ | ថ្នាំការពារ | ០.៣០% | - |
| **សរុប** | | **១០២%** | **១០២%** |

| ប្រភេទជ្រូក | ប្រភេទវត្ថុធាតុដើមសម្រាប់ផ្សំចំណីចិញ្ចឹមជ្រូកខ្នាតតូច | | | | | | |
|---|---|---|---|---|---|---|---|
| | ពោត | សណ្តែក | ចុងអង្ករ | កន្ទក់ | ត្រី ឬម្សៅត្រី | សំបកខ្យង | អំបិល |
| ជ្រូកបា | ១.២២៥ | ០.៥២៥ | ០.៣៥០ | ០.៨៧៥ | ០.៥២៥ | ០.០៧០ | ០.០៥២ |
| មេជ្រូកធើម និងទំនេ | ១.២២៥ | ០.៥២៥ | ០.៣៥០ | ០.៨៧៥ | ០.៥២៥ | ០.០៧០ | ០.០៥២ |
| ជ្រូកសាច់ | ១.២៧៨ | ០.៥២៥ | ០.៣៥០ | ១.២០០ | ០.៥២៥ | ០.០៧០ | ០.០៥២ |
| កូនជ្រូកផ្តាច់ដោះ | ០.៧៥០ | ០.៥០០ | ០.២៥០ | ០.៥០០ | ០.៥០០ | ០.០៥០ | ០.០៣៤ |

**១ - កន្ទក់**

កន្ទក់ជាសារធាតុសម្រាប់ផ្សំចំណីសត្វដែលគេប្រើយ៉ាងទូលំទូលាយនៅក្នុងការផ្តល់ដល់សត្វនៅទូទាំងប្រទេស ក៏ដូចជានៅលើសកលលោកផងដែរ។ ម្យ៉ាងទៀត អ្នកចិញ្ចឹម ឬម្ចាស់សត្វ មិនគួរផ្តល់កន្ទក់ឱ្យសត្វតូចៗ(កូនជ្រូក)ស៊ីទេ ព្រោះប្រដាប់រំលាយអាហាររបស់វានៅមានសភាពខ្សោយក្នុងការរំលាយអាហារដែលមិន អាចកិនរំលាយដែលមានសភាពម៉ត់បានោឡើយ ហើយបណ្តាលឱ្យសត្វជួបប្រទះនូវបញ្ហាផ្លូវប្រដាប់រំលាយ អាហារ។ ចំពោះកូនជ្រូកក្រោយពេលផ្តាច់ដោះ(ចាប់ពីអាយុ ៤៥ថ្ងៃឡើងទៅ) គឺត្រូវផ្តល់ឱ្យវាស៊ីនៅកន្ទក់ដែល មានចុងអង្ករច្រើនមួយរយៈកាល។ ការផ្តល់កន្ទក់ឱ្យកូនជ្រូកមុនដំបូងគេគឺដាក់វាតែបន្តិចបន្តួចប៉ុណ្ណោះ។ បន្ទាប់មក គេនឹងធ្វើការបង្កើនបន្តិចម្តងៗពីមួយថ្ងៃទៅមួយថ្ងៃរហូតដល់សត្វនោះចេះស៊ីចំណី

ពេញលេញទើបយើងអាចផ្តល់ឱ្យវាស៊ីជាធម្មតា។ ក្នុងការផ្តល់កន្ទក់ឱ្យសត្វជ្រូកស៊ីមិនគួរផ្តល់កន្ទក់ឱ្យលើសពី ៣០% ទៅ ៣៥%នៃចំណីរបស់វានោះទេ ព្រោះវាបណ្តាលឱ្យជ្រូកសំបូរទៅដោយជាតិខ្លាញ់ (ខ្លាញ់ច្រើន)។ ប្រសិនបើផ្តល់កន្ទក់ឱ្យជ្រូកស៊ីមានចំនួនច្រើនកាលណា គឺឱ្យជ្រូកនោះគឺវាសំបូរទៅដោយខ្លាញ់ច្រើនកាលនោះ។

## ២ - ចុងអង្ករ

ចុងអង្ករ ជាសារធាតុផ្សំចំណីសម្រាប់ជ្រូកដ៏ល្អបំផុត ព្រោះជ្រូកអាចស៊ីចុងអង្ករល្អិតៗដោយស្រួល ប៉ុន្តែបើអង្ករគ្រាប់ធំៗវិញ គឺត្រូវកិនឱ្យល្អិត ឬត្រាំទឹកក្នុងរយៈពេលពី ៣-៤ម៉ោងសិន ឬយកទៅស្ងោរឱ្យឆ្អិនមុនពេលដាក់ឱ្យជ្រូកស៊ី។ ចុងអង្ករក៏ជាប្រភពថាមពលខ្ពស់ផងដែរ។ ចំពោះការចិញ្ចឹមជ្រូកសាច់ យើងអាចប្រើប្រាស់ចុងអង្កររហូតដល់ទៅ៦០%នៅក្នុងចំណីសម្រាប់ឱ្យវាស៊ី។





## ៣ - ពោត

ពោតមានពីរប្រភេទ គឺពោតស និងពោតក្រហម។ ពោតទាំងពីរប្រភេទនេះមានគុណភាពប្រហាក់ប្រហែលជាទូទៅពោតក្រហមគេច្រើនប្រើប្រាស់សម្រាប់ផលិតជាចំណីសត្វ ហើយមានប្រូតេអ៊ីនពី ៨-៩%។ គេអាចផ្តល់ឱ្យសត្វស៊ីសេរីដោយមិនមានប៉ះពាល់ធ្វីដល់'.ផ្លូវរំលាយអាហារនោះទេ។ ពោតជាចំណីដែលមានរស់ជាតិឆ្ងាញ់ដែលធ្វើឱ្យសត្វជ្រូកចូលចិត្តស៊ី ហើយវាផ្តល់នៅថាមពលខ្ពស់។ ចំពោះគ្រាប់ពោតទុំមុនពេលផ្តល់ឱ្យជ្រូកស៊ី គេត្រូវត្រាំក្នុងទឹករយៈពេលពី៤-៥នាទី ដើម្បីធ្វើឱ្យគ្រាប់ពោតទុំមានសភាពទន់ងាយស្រួលក្នុងការកិនរំលាយដោយក្រពះ។ ពោតជាអាហារសំបូរទៅដោយវីតាមីនបេ(B) ហើយពោតក្រហមមានសារធាតុប្រូវីតាមីន អា(A) ច្រើនជាងពោតស។





### ៤-ជាតិស្ករ

ស្ករមានច្រើននៅក្នុងសមាសធាតុផ្សំចំណីដែលមានដើមកំណើតពីរុក្ខជាតិ។ ជាតិស្ករជាប្រភពផ្តល់ថាមពលយ៉ាងសំខាន់នៅក្នុងចំណីសត្វ។ កំដៅមានសារៈសំខាន់ក្នុងការទ្រទ្រង់សកម្មភាពទាំងអស់ក្នុងខ្លួនសត្វ ដូចជាការសម្របសម្រួលកំដៅក្នុងខ្លួនសត្វ ការធំធាត់ ការផលិតកូន។ល។ ប៉ុន្តែប្រសិនបើនៅក្នុងចំណីសត្វខ្វះនូវថាមពលគឺធ្វើឱ្យសត្វចុះស្គម ចុះខ្សោយ បាត់បង់សមត្ថភាពទប់ទល់ជាមួយមេរោគបង្កជំងឺឆ្លងផ្សេងៗ។

ម្យ៉ាងទៀត ប្រសិនបើជ្រូកទទួលថាមពល (ជាតិស្ករ)លើសពីសេចក្តីត្រូវរបស់វា ថាមពលដែលលើពីត្រូវការនោះវានឹងប្រែក្លាយឱ្យទៅជាជាតិខ្លាញ់ ជាហេតុធ្វើឱ្យជ្រូកសំបូរទៅដោយខ្លាញ់ច្រើន។ អាហារដែលសំបូរទៅដោយថាមពលមានដូចជា ពោត កន្ទក់ ចុងអង្ករ ដំឡូងមី ដំឡូងជ្វា។ល។

ស្ករជាអាហារផ្តល់ថាមពលដ៏សំខាន់ក្នុងការបង្កើតកំដៅនៅក្នុងខ្លួនសត្វ។ ចំពោះការផលិតចំណីសម្រាប់កូនជ្រូក ត្រូវបានគេប្រើប្រាស់ស្កររហូតដល់ទៅប្រមាណ ១០-២០%នៃចំណី។ ចំណែកជ្រូកសាច់ និងជ្រូកធំ គេអាចប្រើប្រាស់រហូតដល់ទៅប្រមាណ៣០%នៃចំណី។





## ៥ បន្លែ

បន្លែដែលគេអាចប្រើប្រាស់ជាចំណីសត្វបានរួមមាន ព្រលិត ផ្ទីរ ផាងត្រាវ ស្ពៃ ខាត់ណា ត្រសក់ឈ្លោកននោង សណ្តែក។ល។ បន្លែសំបូរទៅដោយវីតាមីន និងជាតិរ៉ែ។ គេអាចផ្តល់ឱ្យសត្វក្នុងសភាពស្រស់(ឆៅ)ឬចំអិនឱ្យវាឆ្អិន។ ការផ្តល់បន្លែក្នុងសភាពស្រស់ឱ្យសត្វស៊ី ប្រសើរជាងការផ្តល់ឱ្យសត្វស៊ីក្នុងសភាពឆ្អិន ព្រោះគុណភាពរបស់វាគឺអាចរក្សាភាពដើមរបស់វានៅដដែល។






## ៦ ដំឡូងមី

ដំឡូងមី ជាវត្ថុធាតុដើមសម្រាប់ផ្សំចំណីសត្វដែលសំបូរទៅដោយជាតិស្ករច្រើន ចំណែកដំឡូងមីស្ងួត ឬក្រៀមគឺវាមានជាតិប្រូតេអ៊ីន ២% ហើយមានគុណភាពមិនសូវល្អទេ ប្រសិនបើយើងផ្តល់ឱ្យជ្រូកស៊ីត្រូវមានការប្រុងប្រយ័ត្នបន្តិចព្រោះដំឡូងមីវាមានជាតិពុលដែលធ្វើឱ្យសត្វពុលបាន។ ចំពោះជាតិពុលរបស់ដំឡូងមី គឺវាមានច្រើននៅក្នុងសំបក ហើយប្រសិនបើយើងឱ្យសត្វស៊ីឆៅ ចំពោះកូនជ្រូកអាចបណ្តាលឱ្យពុលងាប់បាន ចំពោះមេដើមអាចបណ្តាលឱ្យរលូតកូន។ ដូច្នេះដើម្បីធ្វើយ៉ាងណាកុំឱ្យសត្វពុលនៅពេលយើងផ្តល់ឱ្យវាស៊ី គឺ ត្រូវបកសំបកចេញ បន្ទាប់មកចិត្តឱ្យស្តើង រួចយកវាទៅហាលនឹងកំដៅថ្ងៃឱ្យស្ងួត ឬស្ងោវាឱ្យឆ្អិន ដើម្បីកាត់បន្ថយជាតិពុលមួយចំនួននៅក្នុងដំឡូងដែលយើងអាចយកទៅផ្សំជាចំណីឱ្យសត្វស៊ី។ ចំពោះកូនជ្រូក និង មេជ្រូកដើមត្រូវផ្តល់ឱ្យស៊ីតែ ៣០% នៅក្នុងចំណីដែលផ្តល់ឱ្យវាស៊ីតែប៉ុណ្ណោះ។ ចំណែកជ្រូកសាច់ ត្រូវផ្តល់ ឱ្យស៊ីតែ ៥០% នៅក្នុងចំណីដែលផ្តល់ឱ្យវាស៊ីតែប៉ុណ្ណោះ។





## ៧)ដំឡូងជ្វា

ដំឡូងជ្វា ជាវត្ថុធាតុដើមដ៏ល្អសម្រាប់ផ្សំជាចំណីសត្វជ្រូក ប៉ុន្តែវាមានជាតិប្រូតេអ៊ីនប្រមាណពី២ ទៅ ២,៥%តែប៉ុណ្ណោះ តែវាសំបូរទៅដោយជាតិស្ករ ហើយយើងអាចផ្តល់ឱ្យជ្រូកស៊ីបានច្រើន។ ដំឡូងជ្វាឆៅ យើងអាចផ្តល់ឱ្យជ្រូកស៊ីមិនបានបង្កមហន្តរាយដល់សត្វទេ ប៉ុន្តែប្រសិនបើយើងធ្វើការស្ងោរឱ្យឆ្អិនល្អជាការ ប្រសើរក្នុងការផ្តល់ឱ្យជ្រូកស៊ី។ ការចិញ្ចឹមជ្រូក អ្នកចិញ្ចឹម ឬម្ចាស់អាចផ្តល់ឱ្យវាស៊ីពី៣៥-៥០%នៅក្នុងចំណី ដែលផ្តល់ឱ្យវាស៊ី។




## ៨)កាកសណ្តែកសៀង ឬសណ្តែកបាយ

សណ្តែកសៀង ជាវត្ថុធាតុដ៏ល្អសម្រាប់ផ្សំជាចំណីសត្វដែលសាធាតុប្រូតេអ៊ីនប្រមាណពី៤០-៥០% ខ្ពស់ជាងពពួកសណ្តែកដ៏ទៃទៀត។ នៅក្នុងគ្រាប់សណ្តែកសៀងស្រស់ មានជាតិក្រពុលម្យ៉ាងដែលគេ ហៅថាទ្រីបស៊ីន ប៉ុន្តែជាតិក្រពុលនេះ យើងអាចកំចាត់វាបានដោយសារកំដៅ។ ហេតុនេះ បើមិនប្រសិន បើយើងមិនបានគាបយកប្រេងចេញពីសណ្តែកសៀងទេ ចាំបាច់ត្រូវយកសណ្តែកសៀងទៅលីងឱ្យឈ្ងុយ មុនពេលយកទៅឱ្យជ្រូកស៊ី។ ជ្រូកចូលចិត្តស៊ីកាកសណ្តែកសៀងណាស់។




## ៩) ត្រី និងម្សៅត្រី

ប្រទេសកម្ពុជាយើង ជាប្រទេសសំបូរទៅដោយត្រីទឹកសាប ត្រីជាប្រភពផ្តល់ប្រូតេអ៊ីនសម្រាប់យកមកផ្សំធ្វើជាចំណីសត្វខ្ពស់(ត្រីក្រៀម ត្រីប្រហុក) ដើម្បីចិញ្ចឹមសត្វឱ្យមានការលូតលាស់ និងធំធាត់លឿន។ គេអាចយកកូនត្រី(ត្រីប្រហុក)មកហាលឱ្យស្ងួត ឬយកទៅឆ្អើរឱ្យស្ងួតហើយកិនឱ្យបានម៉ត់។ គុណភាពរបស់ត្រីគឺមានការប្រែប្រួលទៅតាមប្រភេទត្រី និងទៅតាមរបៀបកែច្នៃ និងជាតិផ្សេងៗទៀតដែល លាយបញ្ចូលជាមួយសាច់ត្រី។ ម្យ៉ាងទៀតនៅក្នុងសាច់ត្រីមានសារធាតុប្រូតេអ៊ីនពី ៤៥-៦០% ហើយម្សៅត្រីដែលមានសភាពល្អគឺមានក្លិនឈ្ងុយ មានជាតិប្រៃតិចជាង៥%។ ចំណែកត្រីសមុទ្រ មានជាតិប្រៃខ្ពស់ និងជាតិប្រូតេអ៊ីនទាប ដូចនេះពេលយកត្រីសមុទ្រមកប្រើប្រាស់ផ្សំជាចំណីសត្វ ត្រូវប្រុងប្រយ័ត្នទៅលើជាតិអំបិល។ ម្សៅត្រីមានគុណភាពល្អ មានជាតិអាស៊ីតអាមីនេសំខាន់ៗគ្រប់គ្រាន់ និងមានកាលស្យូម ផូស្វ័រ និងវីតាមីនបេ១២ (B12)ច្រើនសម្រាប់ជាចំណីសត្វ។ ចំពោះសត្វជ្រូកមិនត្រូវផ្តល់ត្រីឆៅឱ្យវាស៊ីច្រើនពេលទេ ព្រោះវាធ្វើឱ្យជ្រូកមានការរាគរូសគឺដោយសារវាមានខ្លាញ់ច្រើន។






## ១០) កាកសំណល់ផ្ទះបាយ

កាកសំណល់ផ្ទះបាយ ជាចំណីដែលមានរស់ជាតិ និងគុណភាពប្លែកៗគ្នា។ ជាទូទៅគេតែងតែប្រមូលវាពីកាកសំណល់អាហារសល់ពីការហូបចុករបស់មនុស្ស ហើយកាកសំណល់នេះត្រូវគេបានប្រមូលពីសណ្ឋាគារ ភោជនីយដ្ឋានអាហារដ្ឋានជាដើម។ ជាការល្អ មុនពេលផ្តល់ចំណីនេះឱ្យសត្វស៊ីត្រូវស្ងោរចំ អិនជាមុនសិនដើម្បីសម្លាប់មេរោគកុំឱ្យឆ្លងជំងឺដល់សត្វ។





## ១១) ចំណីផ្សំស្រេច

ចំណីផ្សំស្រេច គឺជាចំណីដែលត្រូវបានគេផលិតឡើងទៅតាមរូបមន្តបច្ចេកទេសត្រឹមត្រូវ និងត្រូវបានគេប្រើប្រាស់នៅក្នុងស្ថានីយចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម។ ជាទូទៅចំណីផ្សំស្រេចត្រូវបានផ្សំឡើងពីកន្ទក់ ចុងអង្ករ ពោត សណ្តែកសៀង ឬកាកសណ្តែកសៀង ម្សៅត្រី ប្រេមិច និងម្សៅខ្យង ខ្ចៅ លីស គ្រុំ។ល។ ចំណីផ្សំស្រេចនេះ ត្រូវបានគេផ្តល់ឱ្យសត្វស៊ីសុទ្ធ ឬអាចលាយបន្ថែមដោយបរិមាណបន្តិចបន្តួចជាមួយនឹងចំណីប្រពៃណីយ៍ ដើម្បីបន្ថែមនូវគុណភាពរបស់វា។ ម្យ៉ាងទៀតចំណីផ្សំស្រេចបច្ចុប្បន្នត្រូវបានគេដាក់លក់នៅគ្រប់ទីកន្លែង ហើយជាចំណីដែលមានគុណភាពល្អ តែមានតម្លៃខ្ពស់។





### តារាងតម្រូវការចំណីអាហារសម្រាប់សត្វជ្រូកប្រចាំថ្ងៃ/ក្បាល

| ប្រភេទជ្រូក | តំរូវការចំណីអាហារប្រចាំថ្ងៃ | ផ្សេងៗ |
|---|---|---|
| មេជ្រូកក្រមុំ | ២.៥.៣ គ.ក្រ | |
| ជ្រូកបា | ៤-៤.៥ គ.ក្រ | |
| មេជ្រូកដើម | ៣-៤ គ.ក្រ | |
| មេជ្រូកបំបៅដោះ | ៤-៥ គ.ក្រ | |
| មេជ្រូកផ្តាច់ដោះ | ២.៥-៣ គ.ក្រ | |

### តារាងតម្រូវការចំណីអាហារសម្រាប់កូនជ្រូកប្រចាំថ្ងៃ

| ប្រភេទកូនជ្រូក | តំរូវការចំណីអាហារប្រចាំថ្ងៃ | ផ្សេងៗ |
|---|---|---|
| កូនជ្រូកបៅដោះ | ០.៣-០.៤ គ.ក្រ | |
| កូនជ្រូកអាយុ៧ថ្ងៃ | ០.៥-០.៨ គ.ក្រ | |

| | | |
|---|---|---|
| កូនជ្រូកទំងន់១២-១៨គ.ក្រ | ០.៨-១.២ គ.ក្រ | |
| កូនជ្រូកទំងន់១៨-២៥ គ.ក្រ | ១.២-១.៥ គ.ក្រ | |
| កូនជ្រូកទំងន់២០-៤០គ.ក្រ | ១.៥-២ គ.ក្រ | |
| ជ្រូកទំងន់ ៤០-៦០គ.ក្រ | ៣-៤ គ.ក្រ | |
| ជ្រូកទំងន់ ៦០-៩០គ.ក្រ | ៤ គ.ក្រ | |





- **ទឹក និងការផ្ដល់ទឹក**

ក្នុងសារពាង្គកាយសត្វមានផ្ទុកទឹកពី ៣០%-៧០% ទៅតាមដំណាក់កាល និងអាយុរបស់វា។ ជ្រូកត្រូវការទឹកចាំបាច់នៅពេលអាកាសធាតុក្ដៅហួតហែង និងនៅពេលជ្រូកស៊ីចំណីស្ងួតច្រើន ចំពោះជ្រូកមេត្រូវការទឹកច្រើនសម្រាប់ផលិតទឹកដោះឱ្យកូនបៅ។ ទឹកមានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមយ៉ាងសកម្មក្នុងសមីការប្រតិកម្ម និងបណ្ដូរសារធាតុផ្សេងៗក្នុងសរីរាង្គកាយ។ នៅក្នុងសារពាង្គកាយសត្វខ្វះទឹកនាំឱ្យសត្វមេបំបៅកូនមានទឹកដោះតិច និងមានសភាពខាប់ធ្វើឱ្យមានការលំបាកក្នុងផ្ដល់ទឹកដោះឱ្យកូនបៅ។ ចំពោះជ្រូកចិញ្ចឹមយកសាច់គឺវាស៊ីចំណីតិច ហើយពិបាកក្នុងការរំលាយអាហារ។ ជ្រូកជាសត្វល្មោភស៊ី វាអាចស៊ីចំណីបានច្រើនមុខណាស់សម្រាប់ជាជីវិតរស់។ ម្យ៉ាងទៀតសត្វជ្រូកអាចស៊ីចំណីដែលមានដើមកំណើតពីសត្វ និងចំណីដែលមានដើមកំណើតពីរុក្ខជាតិ។ ដូចនេះយើងត្រូវផ្ដល់ទឹកឱ្យបានគ្រប់គ្រាន់សម្រាប់ជួយសម្រួលក្នុងរំលាយអាហារ និងប្រព័ន្ធឈាមរត្តក្នុងសារពាង្គកាយសត្វ។





### តារាងតម្រូវការទឹកសម្រាប់សត្វជ្រូកប្រចាំថ្ងៃ/ក្បាល

| ប្រភេទជ្រូក | ជ្រូកតម្រូវការទឹកប្រចាំថ្ងៃ/ក្បាល | ផ្សេងៗ |
|---|---|---|
| មេក្រមុំ | ១០-១៥លីត្រ | |
| ជ្រូកបា | ១៥-២០លីត្រ | |
| មេដើម | ១៥-២៥លីត្រ | |
| មេបំបៅកូន | ៣០-៤០លីត្រ | |
| កូនជ្រូកផ្តាច់ដោះ | ០.២-០.៤លីត្រ | |
| កូនជ្រូកអាយុពី៧ថ្ងៃទំងន់១២គ.ក្រ | ១-២លីត្រ | |
| កូនជ្រូកទំងន់១២-១៨គ.ក្រ | ២-៣លីត្រ | |
| កូនជ្រូកទំងន់១៨-២៥គ.ក្រ | ៣-៤លីត្រ | |
| កូនជ្រូកទំងន់២៥-៤៥គ.ក្រ | ៤-៦លីត្រ | |
| កូនជ្រូកទំងន់៤៥-១០០គ.ក្រ | ៦-១០លីត្រ | |

- **ការចងចាំ**
  - ក្រៅអំពីចំណីដែលបានរៀបរាប់ខាងលើគឺនៅមានចំណីជាច្រើនដែលសត្វអាចស៊ីបាន
  - សូមធ្វើការប្រុងប្រយ័ត្នជានិច្ចចំពោះចំណីដែលប្រើប្រាស់ ត្រូវពិនិត្យឱ្យបានច្បាស់ក្រែងចំណី នោះមានសភាពជូរផ្អូម ដុះផ្សិត រលួយស្អុយដែលជាប្រភេទចំណីខូចគុណភាព ហើយអាចធ្វើឱ្យចំណីនោះ ជាអាហារពុលដល់សត្វ ជួនកាលអាចបណ្តាលឱ្យសត្វស្លាប់បានទៀតផង។
  - ប្រសិនបើអ្នកទិញកូនជ្រូកនៅតូចពេក(មិនទាន់គ្រប់អាយុត្រូវផ្តាច់ដោះ)មកចិញ្ចឹម ហើយវាមិនទាន់ចេះស៊ីចំណីស្រួលបួល អ្នកត្រូវតែបបរឱ្យរលួយរាវៗយកមកលាយជាមួយស្ករបន្តិចមកបញ្ចុកវាឱ្យបានច្រើនដងក្នុងមួយថ្ងៃដែលអាចធ្វើទៅបានរហូតដល់វាចេះស៊ីចំណីត្រឹមត្រូវដោយខ្លួនឯងទើបយើងអនុវត្តការផ្តល់ចំណីធម្មតាដល់វា។
  - ត្រូវផ្តល់ចំណីដល់ជ្រូកឱ្យបានទៀតទាត់ពេលវេលា ចំណីត្រូវធានាបានទាំងបរិមាណ និងគុណភាព
  - បើយើងផ្តល់ចំណីឱ្យជ្រូមិនបានគ្រប់គ្រាន់ទៅតាមតម្រូវការរបស់វាទេនោះ វានឹងបណ្តាលឱ្យជ្រូកក្រធំនិងបណ្តាលឱយសត្វចុះខ្សោយដែលជាមូលហេតុនៃការលេចចេញឡើងនៃជំងឺផ្សេងៗដល់សត្វ។
  - មិនត្រូវផ្តល់ចំណីហួសពីតម្រូវការរបស់សត្វឡើយ ព្រោះចំណីដែលនៅសេសសល់នៅក្នុងស្នូកចំណីធ្វើជូរផ្អូម ឬដុះផ្សិត ហើយអាចធ្វើឱ្យសត្វផ្សេងៗទៀតចូលមកស៊ីចំណីប្រឡាក់ប្រឡូកដែលអាចបណ្តាលឱ្យសត្វឆ្លងជំងឺផ្សេងៗទៀត។

## ៦. សុខភាពសត្វ

### ៦.១.១ អនាម័យ និងការថែទាំ

ការធ្វើអនាម័យ និងការថែទាំសត្វជាកត្តាសំខាន់ ដែលអាចធ្វើឱ្យសត្វមានសុខភាពល្អ និងទទួលបានភាពជោគជ័យក្នុងការចិញ្ចឹមសត្វ ដូច្នេះរយៈពេល៧ថ្ងៃមុនដាក់សត្វចិញ្ចឹម យើងត្រូវធ្វើការសម្លាប់មេរោគដោយប្រើថ្នាំបាញ់ TH4, Crysol ឬបាចកំបោរ ត្រូវធ្វើការសំអាតសំភារៈប្រើប្រាស់នៅកន្លែងចិញ្ចឹម និងនៅបរិវេណជុំវិញកន្លែងចិញ្ចឹម។ បរិវេណកន្លែងចិញ្ចឹមពេលមនុស្សចេញ-ចូល ត្រូវប្តូរស្បែកជើង និងសំលៀកបំពាក់ចេញ និងត្រូវធ្វើការសម្លាប់មេរោគនៅតាមផ្លូវដើរ។ មិនត្រូវមានសំឡេងខ្លាំងៗនាំឱ្យភ្ញាក់ផ្អើលដល់សត្វត្រូវលាងសំអាតស្នូកទឹក និងស្នូកចំណីជាប្រចាំ ត្រូវធ្វើយ៉ាងណាឱ្យពន្លឺថ្ងៃ និងខ្យល់អាកាសចេញ ចូលឱ្យបានគ្រប់គ្រាន់ត្រូវផ្តល់ចំណីនិងទឹកស្អាតឱ្យបានគ្រប់គ្រាន់ដល់សត្វជាពិសេសនៅរដូវខ្សត់ទឹក (រដូវប្រាំង)។







### ៦.១.២ វិធានការពារ

នៅលើពិភពលោក ក៏ដូចជាព្រះរាជាណាចក្រកម្ពុជាដែរ មានមេរោគជាច្រើនប្រភេទបានរាតត្បាតដល់ការចិញ្ចឹមសត្វដូចជា៖ Parasite, Proto, Bacteria, Virus ដូច្នេះការចិញ្ចឹមសត្វដាច់ខាតត្រូវតែប្រើប្រាស់ឱសថសម្រាប់ការពារទើបធានាដល់ការចិញ្ចឹម។ ប្រភេទឱសថដែលត្រូវប្រើរួមមាន៖ Vaccine, Vitamin, Mineral និងធ្វើការទំលាក់ Parasite។

• **វ៉ាក់សាំង**

ការចិញ្ចឹមសត្វត្រូវប្រើប្រាស់វ៉ាក់សាំងសម្រាប់ការពារជំងឺឆ្លងទៅតាមអាយុសត្វដូចមាននៅក្នុងតារាងខាងក្រោម៖

**តារាងនៃការប្រើប្រាស់វ៉ាក់សាំងការពារជំងឺឆ្លងសត្វជ្រូក**

| អាយុជ្រូក | ប្រភេទជំងឺ |
|---|---|
| មុនពេលដាក់បា | ចាក់ថ្នាំការពារជំងឺសារទឹកភាល់១ឆ្នាំម្តង ។ |
| មេជ្រូកដើមបាន ១២ អាទិត្យ | ចាក់ថ្នាំការពារជំងឺអុតក្តាម ។ |
| ក្រោយពីកើតកូន២អាទិត្យ | ចាក់ថ្នាំការពារជំងឺប៉េស្ត ។ |

**តារាងនៃការប្រើប្រាស់វ៉ាក់សាំងការពារជំងឺឆ្លងកូនជ្រូក**

| ប្រភេទជ្រូក | អាយុ | វ៉ាក់សាំង | រយៈពេល |
|---|---|---|---|
| កូនជ្រូកផ្តាច់ដោះ | ១ខែ | Salmonellosis | រំលឹក៦ខែម្តង |
| កូនជ្រូកផ្តាច់ដោះ | ១ខែដប់ថ្ងៃ | Pasteurelloze | រំលឹក៦ខែម្តង |
| កូនជ្រូកផ្តាច់ដោះ | ១ខែម្ភៃថ្ងៃ | Peste | រំលឹក៦ខែម្តង |
| កូនជ្រូក | ក្រោម៣ខែកន្លះ | FMD | រំលឹក៦ខែម្តង |
| កូនជ្រូក | ក្រោម៤ខែ | Aujesky | រំលឹក៦ខែម្តង |





**កម្មវិធីចាក់វ៉ាក់សាំងការពារជម្ងឺជ្រូកមេ**




**កម្មវិធីចាក់វ៉ាក់សាំងការពារជម្ងឺជ្រូកសាច់**







៖ -កូនជ្រូកអាយុពី១-៣ថ្ងៃចាក់ហ្វែរលើកទី១=១សេសេ

-ចាក់ហ្វែរលើកទី២ក្រោយលើកទី១ រយៈពេល១០ថ្ងៃ

-ចាក់ទំលាក់ប៉ារ៉ាស៊ី២-៤ដងក្នុង១ឆ្នាំ

- **ឱសថសម្លាប់ និងទំលាក់** Parasite:

ដើម្បីកាត់បន្ថយ Parasite នៅក្នុងខ្លួនសត្វពេលកូនកូនជ្រូកផ្តាច់ដោះត្រូវចាក់ថ្នាំ Ivomex ហើយរំលឹករៀងរាលបីខែម្តង។ ចំពោះមេជ្រូកត្រូវចាក់ថ្នាំសំលាប់/ទំលាក់Parasite មុនពេលមេជ្រូកដោយឈ្មោល និងនៅពេលផ្តាច់ដោះ

• **វីតាមីន និង សារធាតុរ៉ែ**

ចំពោះកូនជ្រូកមានអាយុពី ៣ ទៅ ៧ថ្ងៃ ត្រូវចាក់ជាតិដែក (F) និងត្រូវរំលឹកឡើងវិញនៅអាយុពី ១៥ ទៅ២១ថ្ងៃ។ ត្រូវផ្តល់Mutivitamin ឱ្យវាផឹកនៅរយៈពេលបំបៅដោះកូន ធ្វើឱ្យសត្វមានសុខភាពល្អ ធំធាត់លឿន និងធនទៅនឹងជំងឺឆ្លងផ្សេងៗ មេជ្រូកដោយឈ្មោលចាក់ A.D.E ជាជំនួយដើម្បីធ្វើឱ្យសត្វមានសុខភាពរឹងមាំ។





• **ចូរចាំថា៖**

ជាធម្មតា កូនជ្រូកត្រូវការជាតិដែកពី៧ ទៅ ៩មីលីក្រាម/ថ្ងៃ រីឯជាតិដែកដែលមេវាផ្តល់ឲ្យតាមរយៈទឹកដោះបានតែ១ ទៅ២មីលីក្រាម/ថ្ងៃ ដូច្នេះ ត្រូវចាក់ជាតិដែកបន្ថែមដល់កូនជ្រូកនៅពេលវាមានអាយុ ៣ថ្ងៃ និងចាក់លើកទី២ នៅអាយុ ២១ថ្ងៃ ខ្វះជាតិដែកធ្វើឲ្យកូនជ្រូកក្រិន ក្រធំ និងកើតជំងឺរាគ ។

# ឯកសារយោង

១- សៀវភៅស្តីពីការចិញ្ចឹមជ្រូករបស់ការិយាល័យផលិតកម្មនៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ដែលរៀបចំ និងកែសម្រួលដោយលោក គង់ វ៉ាន់ថន ប្រធានការិយាល័យផលិតកម្ម។

២- សៀវភៅម៉ូឌុលសម្រាប់បណ្តុះបណ្តាលរំលឹកភ្នាក់ងារសុខភាពសត្វភូមិដែលបានរៀបចំដោយគម្រោងចិញ្ចឹមសត្វកម្ពុជា ឆ្នាំ២០១០។

៣- Feeding standards for Australian livestock, Prepared by Standing Committee on Agriculture pig Subcommitte

៤- វិធីសាស្ត្រក្នុងការថែទាំ និងគ្រប់គ្រងមេជ្រូកមុននិងក្រោយពេលកើតកូនដែលបានរៀបចំដោយកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ២០០៩។

៥- សៀវភៅគន្លឹះការចិញ្ចឹមជ្រូកដែលរៀបចំដោយក្រុមហ៊ុន ស៊ី.ភីខេមបូឌា ចំកាត់។

៦- សៀវភៅបច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ ដែលរៀបចំដោយនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ឆ្នាំ២០១៣។

៧- សៀវភៅបច្ចេកទេសចិញ្ចឹមមាន់ ជ្រូក និងគោជាលក្ខណៈគ្រួសារ ដែលរៀបចំដោយនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល សហការជាមួយអគ្គនាយកដ្ឋានកសិកម្មឆ្នាំ២០១៣។

៨- សៀវភៅស្តីពីបច្ចេកទេសចិញ្ចឹម និងដាំដុះតាមលក្ខណៈគ្រួសារដែលរៀបចំដោយ លោក គង់អ៊ួក ប្រធាននាយកដ្ឋានអង្គការក្រៅរដ្ឋាភិបាល និងសិទ្ធិមនុស្សណែទីស្តីការគណៈរដ្ឋមន្ត្រី។

៩- សៀវភៅស្តីពីការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារដែលរៀបចំដោយអង្គការទស្សនៈពិភពលោក។

១០- សៀវភៅស្តីពីការចិញ្ចឹមសត្វ និងការព្យាបាលដែលរៀបចំដោយលោកទេព វិចិត្រមុន្នី។

១១សៀវភៅឯកសារបំពាក់បំប៉នបន្ថែមគ្រូបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិដែលរៀបចំដោយគម្រោងបង្កើនផលិតភាពកសិកម្ម ផ្នែកផលិតកម្មនិងបសុព្យាបាលនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០២